ក

មាតិកា

I.ក្រុមប្រឹក្សាធម្មនុញ្ញ

០១-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣២/០០៧/២០១៣ កបធ.ច ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣៤/០៣៨/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៣៩៣

០១-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣៣/០០៨/២០១៣ កបធ.ច ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២២៧/០៣១/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៤០០

០២-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣៤/០០៩/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣៥/០៣៩/២០១៣ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១៣ ៨៤០៦

០២-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣៥/០១០/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣២/០៣៦/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៤១២

០២-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣៦/០១១/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២២៨/០៣២/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៤១៩

០២-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣៧/០១២/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣៦/០៤០/២០១៣ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ៨៤២៥

០២-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣៨/០១៣/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២២៩/០៣៣/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៤៣២

II.រាជរដ្ឋាភិបាល

អនុក្រឹត្យ

-អនុក្រឹត្យលេខ ៤៧៨ អនក្រ.បក មិនទាន់បានទទួល

០១-៩-២០១៣ -អនុក្រឹត្យលេខ ៤៧៩ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨៤៣៧

០៦-៩-២០១៣ -អនុក្រឹត្យលេខ ៤៨០ អនក្រ.បក ស្ដីពី ការទទួលស្គាល់សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ៨៤៣៩
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៦០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨៤៤២
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៦១ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៨៤៤៣
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៦២ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៤៥០
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៦៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨៤៥៦
០៣-៧-២០១៣-អនុក្រឹត្យលេខ ៨៦៤ អនក្រ.តត ស្ដីពី ការតែងតាំងជំនួយការក្រសួងមហាផ្ទៃ ៨៤៦២
០៣-៧-២០១៣-អនុក្រឹត្យលេខ ៨៦៥ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៨៤៦៣
០៣-៧-២០១៣-អនុក្រឹត្យលេខ ៨៦៦ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៨៤៦៥
០៣-៧-២០១៣-អនុក្រឹត្យលេខ ៨៦៧ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៨៤៦៨
០៤-៧-២០១៣ -អនុក្រឹត្យលេខ ៨៦៨ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៨៤៦៩

III~ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៦-៨-២០១៣ -ប្រកាសលេខ ៦៤៨ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ចាផាណោ (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់កីឡា, ស្រោមដៃកីឡា ៨៤៧០
១៦-៨-២០១៣ -ប្រកាសលេខ ៦៤៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីកូ (ភ្នំពេញ) ខូអិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៨៤៧៤
១៦-៨-២០១៣ -ប្រកាសលេខ ៦៥០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ្រាន់ កែកឃិជីង (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្ភារៈវេចខ្ចប់ពីផ្លាស្ទិក ៨៤៧៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ:១១៧/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

សូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល

<u>កម្មវត្ថុ</u> : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣២/០០៧/២០១៣ កបធ.ច ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

<u>យោង</u> : មាត្រា ៣៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១៧ និង ៥០ នាទី ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យបណ្តឹង ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក ឡុង ប៊ុន្នី ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រៃវែង និង បានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

អគ្គលេខាធិការ

ថាន់ វិសុី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ:២៣៤/០៣៨/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

សេចក្តីសម្រេច

លេខ:១៣២/០០៧/២០១៣ កបធ.ច

ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញលិខិតលេខ ៨២៤/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **ឡុង ម៉ុន្នី** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រៃវែង

-បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោក **ឡុង ម៉ុន្នី** ជាតំណាងគណបក្សសង្គ្រោះជាតិក្នុងការដាក់ពាក្យបណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រៃវែង

-បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៥៥/១៣ គ.ជ.ប ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣

-បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ឡុង ម៉ុន្នី** កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយឯកសារភស្តុតាងចំនួនបីរយម្ភៃប្រាំបីទំព័រ

-បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **សោម ចំនួឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ចំនួនប្រាំពីរទំព័រ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **ឡុង ម៉ុន្នី** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៥ និង ៣៧ នាទី គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងចំណុចទី២ មាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

-យល់ឃើញថា បណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺទាមទារ ៨ ចំណុច ប្រមូលផ្តុំលើ បញ្ជីឈ្មោះសម្រាប់ការបោះឆ្នោត ការចេញលិខិតបញ្ជាក់អត្តសញ្ញាណ មានក្រុមមនុស្សថ្មីៗ ចេញទៅ បោះឆ្នោត ប្រធានភូមិ អនុប្រធានភូមិឈរមុខមណ្ឌលកត់ឈ្មោះប្រជាពលរដ្ឋចូលបោះឆ្នោត ករណីនៅ ការិយាល័យលេខ ០៩៣៤ នៅក្រុងព្រៃវែង បិទទ្វារបង្អួចនៅពេលរាប់សន្លឹកឆ្នោត ការចេញលិខិតបញ្ជាក់ អត្តសញ្ញាណឱ្យជនជាតិវៀតណាម លើទម្រង់ ១១០៤ អត់បានបោះត្រា និង មិនបំពេញទិន្នន័យគ្រប់ និង មានអ្នកដែលគេបោះឆ្នោតជំនួស ។ ដើមបណ្តឹងលើកសំណូមពរ ៥ចំណុចៈ សូមពិនិត្យឡើងវិញនូវបញ្ជី បោះឆ្នោតឡើងវិញសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ សូមផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលបោះឆ្នោត សម្រាប់ស្រុកមេសាង សូមឱ្យរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យលេខ ០៩៣៤ សូមឱ្យបោះឆ្នោត ឡើងវិញនៅស្រុកកំចាយមារទាំងស្រុង និង សូមឱ្យអ្នកមិនបានបោះឆ្នោតបានបោះឆ្នោតឡើងវិញ

-យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **សោម ចំនួនឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ចំនួនប្រាំពីរទំព័រ បានបញ្ជាក់ថា ការប្តឹងតវ៉ាពីបញ្ជីឈ្មោះបោះឆ្នោតត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះ ឆ្នោតប្រចាំឆ្នាំ ។ បញ្ហានេះផ្អែកតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់ការបោះ ឆ្នោត ឆ្នាំ២០១៣ គឺផុតអាជ្ញាយុកាលតវ៉ាហើយ ។ អំពីភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្ត-សញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ការដែលថាមានអ្នកមកបោះឆ្នោតជំនួស ដើមបណ្តឹងពុំបានផ្តល់ ភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ថា អ្នកកាន់លិខិតបញ្ជាក់អត្តសញ្ញាណទៅបោះឆ្នោតនៅការិយាល័យ ណាមួយទេ និង អ្នកបោះឆ្នោតជំនួសក៏មិនដឹងថាបោះឆ្នោតនៅការិយាល័យណាមួយដែរ ។ ចំពោះទម្រង់ ១១០៤ តំណាង គ.ជ.ប បានបញ្ជាក់ថានេះគ្រាន់តែជាឯកសារចម្លងទិន្នន័យពីទម្រង់ ១១០២ តែប៉ុណ្ណោះ។ ភស្តុតាងដែលដើមបណ្តឹងបង្ហាញតាមរយៈទម្រង់ ១១០៤ បីសន្លឹកមិនបានបោះត្រា និងទម្រង់ ១១០៤ ខ្លះមិនបានបំពេញព័ត៌មានគ្រប់ គ្រាន់តែជាកំហុសផ្នែករដ្ឋបាលប៉ុណ្ណោះ ។ ចំពោះការសុំផ្ទៀងផ្ទាត់ឡើង វិញលទ្ធផលបោះឆ្នោតក្នុងស្រុកមេសាង ការរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យ ០៩៣៤ ការសុំឱ្យ បោះឆ្នោតសាជាថ្មីនៅស្រុកកំចាយមារទាំងស្រុង និង សុំឱ្យអ្នកមិនបានបោះឆ្នោតអាចទៅបោះឆ្នោត ឡើងវិញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចទទួលសំណូមពរនេះបានឡើយ ពីព្រោះដើម បណ្តឹងពុំមានទឡ្ហីករណ៍សមហេតុផលដូចមានចែងក្នុងច្បាប់បោះឆ្នោតទេ ។ ការលើកឡើងអំពីភាពមិន ប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែង ដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និង អាស័យដ្ឋាននៃសាក្សី ព្រមទាំងឯកសារ និង ភស្តុតាងដទៃទៀត ដើមបណ្តឹងមិនមានអ្វីយកមកបញ្ជាក់ឱ្យត្រូវតាមបទប្បញ្ញត្តិ មាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រទេ ។

-យល់ឃើញថា នៅមណ្ឌលខេត្តព្រៃវែងមាន ១.៦០៥ ការិយាល័យ ការបោះឆ្នោតពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៧១,២១ ភាគរយ

-យល់ឃើញថា លិខិតលេខ ៨២៤/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

សម្រេច

មាត្រា ១.- ទទួលពាក្យបណ្តឹងរបស់លោក **ឡុង ប៊ុន្នី** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២.- តម្កល់លិខិតលេខ ៨២៤/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣.- សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ ...
ថ្ងៃ..២៧..សីហា ២០១៣
បញ្ជូន...

ពាក្យបណ្តឹងតវ៉ា

ខ្ញុំបាទឈ្មោះ **ឡុង ម៉ុន្នី** អាយុ៤៣ឆ្នាំ ជាតំណាងគណបក្សសង្គ្រោះជាតិ មានទីលំនៅផ្ទះលេខ៤AZ ផ្លូវលេខ២២០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

សូមគោរពចូលមក

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ ៖ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលព្រៃវែង ។

យោង ៖ - សម្រង់សេចក្តីសម្រេចលេខ៨២៤/១៣ គ.ជ.ប. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

- ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម សម រង្ស៊ី ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទបានដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាមទារ ៖

១. បញ្ជីឈ្មោះសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ មានភាពមិនប្រក្រតី ដូចជាមានឈ្មោះស្ទួន និងបាត់ឈ្មោះច្រើន ។

២. មានភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ។

៣. មានក្រុមមនុស្សថ្មីៗដែលមិនស្ថិតនៅក្នុងភូមិឃុំនោះ ចេញមកបោះឆ្នោតនៅស្រុកកញ្ជៀច ឃុំក្បៀងរាយ និង ស្រុកមេសាង ឃុំព្រៃរំដេង ។

៤. មានមេភូមិ អនុភូមិ ឈរនៅមុខមណ្ឌលដើម្បីឈរកត់ឈ្មោះប្រជាពលរដ្ឋដែលបានចូលមកបោះឆ្នោត ។

៥. មានការបិទទ្វារ និងបង្អួចនៅពេលកំពុងរាប់សន្លឹកឆ្នោតនៅការិយាល័យលេខ០៩៣៤ ក្នុងមណ្ឌលសាលាបឋមសិក្សាក្រុងព្រៃវែង ខេត្តព្រៃវែង ។

៦. មានចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើការឲ្យបោះឆ្នោតដល់ជនជាតិវៀតណាម ។

៧. ក្នុងទម្រង់លេខ១១០៤ សង្កេតឃើញថា អត់មានបោះត្រា និងមិនបានបំពេញព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ ។

៨. មានអ្នកដែលគេបោះឆ្នោតជំនួស ។

ខ្ញុំបាទទាមទារយ៉ាងនេះដោយសំអាងថា:

១. សូមឲ្យពិនិត្យឡើងវិញនូវបញ្ជីបោះឆ្នោតឆ្នាំ២០១២ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ ។

២. សូមឲ្យផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលសម្រាប់ស្រុកមេសាង ខេត្តព្រៃវែង ។

៣. សូមឲ្យរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យលេខ០៩៣៤ ។

៤. សូមឲ្យបោះឆ្នោតឡើងវិញនៅស្រុកកំចាយមារទាំងស្រុង និងសូមឲ្យអ្នកមិនបានបោះឆ្នោតបានបោះឆ្នោតឡើងវិញ ។

ក្រោយពីបានដាក់ពាក្យបណ្តឹងមក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំ ។ ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលនេះទេ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាទទួលយកនូវពាក្យបណ្តឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្តីអនុគ្រោះ ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

ហត្ថលេខា

សូមជូនភ្ជាប់មកជាមួយនូវឯកសារថតចម្លង

- *សម្រង់សេចក្តីសម្រេចលេខ៨២៤/១៣* *ចំនួន០១ច្បាប់។*
- *ពាក្យបណ្តឹង* *ចំនួន០១ច្បាប់។*
- *លិខិតផ្ទេរសិទ្ធិ* *ចំនួន០១ច្បាប់។*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខៈ១១៦/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

សូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល

កម្មវត្ថុ : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣៣/០០៨/២០១៣ កបធ.ច ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

យោង : មាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋា-ភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១៥ រសៀល ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យបណ្តឹង ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ដែលប្តឹងជំទាស់លទ្ធផលបោះឆ្នោតបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ និងបានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

អគ្គលេខាធិការ

ចាន់ រីស៊ី

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១. E-mail: sgccc@online.com/ info@ccc.gov.kh, Website :http://www.ccc.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ២២៧/០៣១/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

សេចក្តីសម្រេច

លេខ : ១៣៣/០០៨/២០១៣ កបធ.ច

ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញលិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ប្តឹងតវ៉ានឹងលទ្ធផលបោះឆ្នោតបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **រស់ សួ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពង់ស្ពឺ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៦២/១៣ គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **រស់ សួ** កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៤៥ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ នៃមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃបណ្តឹងរបស់លោក **រស់ សួ** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារដូចតទៅ : ១-សើរើបញ្ជី

ឈ្មោះផ្លូវការឆ្នាំ២០១២ ឱ្យត្រឹមត្រូវ ដែលបានបាត់ឈ្មោះ និងឈ្មោះអ្នកបោះឆ្នោត បោះឆ្នោតជំនួសឈ្មោះគេ ២-សើរើបញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ ខុសឈ្មោះ និងឈ្មោះស្ទួនច្រើន និង ៣-ផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតបណ្ដោះអាសន្នតាមទម្រង់ ១១០៤ ឡើងវិញ។ ដើមបណ្ដឹងសំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ មេត្តាពិនិត្យ និងពិចារណាឡើងវិញ នូវសេចក្ដីសម្រេច(តាមពិតជាលិខិត)របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលផ្ទុយពីបទបញ្ជា និងនីតិវិធីដែលច្បាប់បានកំណត់។ ដើមបណ្ដឹងពុំមានភស្តុតាងអ្វីប្រគល់ជូនក្រុមប្រឹក្សាធម្មនុញ្ញទេ

- យល់ឃើញថា ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញដោយបញ្ជាក់ថា : ការប្ដឹងតវ៉ាពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះ ត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ ដើមបណ្ដឹងមិនបានកំណត់ការិយាល័យណាមួយច្បាស់លាស់ ឈ្មោះ និងលេខរៀងក្នុងបញ្ជីឈ្មោះប្រជាពលរដ្ឋនោះឡើយ។ ករណីមានអ្នកបោះឆ្នោតជំនួស ដើមបណ្ដឹងពុំមានភស្តុតាងច្បាស់លាស់ដើម្បីបញ្ជាក់ថា ករណីនេះកើតឡើងនៅការិយាល័យណាមួយដែលអាចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពិនិត្យ និងវាយតម្លៃផលប៉ះពាល់លើលទ្ធផលបោះឆ្នោតបានឡើយ ហើយដើមបណ្ដឹងក៏មិនបានចាំចំនួន និងឈ្មោះទេ តែបញ្ជាក់ថា មានចំនួនតិចតួច។ ចំពោះការតវ៉ាលើទម្រង់ ១១០៤ ដែលមានលទ្ធផលខុសពីការប្រកាសរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើមបណ្ដឹងពុំបានផ្ដល់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធ្វើជាមូលដ្ឋានពិចារណាសម្រេចតាមច្បាប់បានឡើយ។ ដើមបណ្ដឹងមិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា នៅមណ្ឌលខេត្តកំពង់ស្ពឺសរុបមាន ១.០៦៧ ការិយាល័យ ការបោះឆ្នោតពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៧៦,៦៧ ភាគរយ

- យល់ឃើញថា លិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

សម្រេច

មាត្រា ១.- ទទួលពាក្យបណ្តឹងរបស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២.- តម្កល់លិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ 447/031/2013
ថ្ងៃ 14 សីហា 2013
បញ្ជូន 2:45 ...

ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ **រស់ សួ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ ៖ សុំប្តឹងជំទាស់លទ្ធផលឆ្នោតបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ ។

យោង ៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ

-បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥

-លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់លោក **សម រង្ស៊ី** ផ្ទេរសិទ្ធិជូន លោក **រស់ សួ**

-ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ខេត្តកំពង់ស្ពឺ

-សេចក្តីសម្រេចលេខ៖៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ លោក **នុត រំដួល** ប្រធានក្រុមការងារគណបក្សសង្គ្រោះជាតិ ខេត្តកំពង់ស្ពឺ បានដាក់ពាក្យបណ្តឹងតវ៉ា ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ.ជ.ប ទាមទារ ៖

១- សើរើបញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ ឲ្យត្រឹមត្រូវ ដែលបានបាត់ឈ្មោះ និងឈ្មោះអ្នកបោះឆ្នោត បោះឆ្នោតជំនួសឈ្មោះគេ

២- សើរើបញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ ខុសឈ្មោះ និងឈ្មោះស្ទួនច្រើន

៣- ផ្ទៀងផ្ទាត់លទ្ធផលឆ្នោតបណ្តោះអាសន្ន តាមទម្រង់១១០៤ ឡើងវិញ

សេចក្តីសម្រេចលេខ៖ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានបដិសេធបណ្តឹងតវ៉ា សុំទាមទារទាំង ៣ (បី)ចំណុចខាងលើ ដែលមានភាពមិនប្រក្រតី ទូទាំងខេត្តកំពង់ស្ពឺ ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងពិចារណាឡើងវិញ នូវសេចក្តីសម្រេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ដែលផ្ទុយពីបទបញ្ញា និងនីតិវិធី ដែលច្បាប់បានកំណត់ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ៕

រាជធានីភ្នំពេញ,ថ្ងៃទី.១៧.ខែសីហា ឆ្នាំ២០១៣

ស្នាមមេដៃស្តាំ

រស់ សួ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាន

លេខ: ១១៧ /២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

សូមគោរពជូន

ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល

កម្មវត្ថុ : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣៤/០០៩/២០១៣ កបធ.ច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

យោង : មាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យបណ្តឹងចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៣ របស់លោក **ខឹម ញៀង** ដែលប្តឹងបដិសេធនឹងសេចក្តីជូនដំណឹង លេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង បានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

អគ្គលេខាធិការ

ចាន់ វិស៊ី

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១. E-mail: sgccc@online.com/ info@ccc.gov.kh, Website :http://www.ccc.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ២៣៥/០៣៩/២០១៣

ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣

សេចក្តីសម្រេច

លេខ : ១៣៤/០០៩/២០១៣ កបធ.ច

ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ របស់លោក **ងឹម ញេង** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តពោធិសាត់
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **ងឹម ញេង** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តពោធិសាត់
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៧៣/១៣ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ងឹម ញេង** កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ របស់លោក **ងឹម ញេង** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួល នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១០ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ មាត្រា ២៧ ថ្មី

នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោក **ងឹម ញ៉េង** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារដូចតទៅ : ទី១ បដិសេធលទ្ធផលការបោះឆ្នោតនៅមណ្ឌលខេត្តពោធិសាត់ ទី២ ឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តពោធិសាត់ឡើងវិញ និងទី៣ ឱ្យបោះឆ្នោតឡើងវិញទូទាំងខេត្តពោធិសាត់ ។ ដើមបណ្តឹងទាមទារយ៉ាងនេះដោយសំអាងថា ១-នៅមណ្ឌលខេត្តពោធិសាត់ទាំងមូលមានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោត ឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុច្បាស់លាស់ ២-នៅការិយាល័យមួយចំនួន ប្រធានការិយាល័យបោះឆ្នោតបានអនុញ្ញាតឱ្យអ្នកកាន់លិខិតបញ្ជាក់អត្តសញ្ញាណមិនត្រឹមត្រូវបោះឆ្នោត ហើយខ្ញុំបាទបានប្តឹងបដិសេធលទ្ធផលបោះឆ្នោត តាមឋានានុក្រមរួចហើយ តែត្រូវគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់បដិសេធ ៣-ករណីទំនាស់ផលប្រយោជន៍រវាងគណៈកម្មការរៀបចំការបោះឆ្នោតខេត្តពោធិសាត់ និងបេក្ខជនតំណាងរាស្ត្ររបស់គណបក្សនយោបាយ និង ៤-ករណីមានឈ្មោះជនបរទេសច្រើននៅក្នុងបញ្ជីបោះឆ្នោត។ ដើមបណ្តឹងពុំមានភស្តុតាងអ្វីប្រគល់ជូនក្រុមប្រឹក្សាធម្មនុញ្ញទេ

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ បានបញ្ជាក់ថា : ការប្តឹងតវ៉ារបស់លោក **ងឹម ញ៉េង** ទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅមណ្ឌលខេត្តពោធិសាត់ ដើមបណ្តឹងលើកមូលហេតុថា នៅការិយាល័យលេខ ០៣០១ ០៦២១ ០៤១១ ០៤១២ និង ០៣០៧ ក្នុងឃុំផ្ទះព្រៃ និងឃុំរលាប ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនេះបានអនុញ្ញាតឱ្យប្រជាពលរដ្ឋកាន់លិខិតបញ្ជាក់អត្តសញ្ញាណមិនត្រឹមត្រូវបានបោះឆ្នោត។ ផ្អែកតាមពាក្យបណ្តឹង និងចម្លើយរបស់លោក **ងឹម ញ៉េង** ព្រមទាំងឯកសារភស្តុតាង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចបដិសេធបណ្តឹង ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ ដោយហេតុថា : ១-ការអះអាងរបស់លោក **ងឹម ញ៉េង** ថា ប្រធានការិយាល័យបោះឆ្នោតបានអនុញ្ញាតឱ្យប្រជាពលរដ្ឋកាន់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតមិនត្រឹមត្រូវបានបោះឆ្នោតនៅការិយាល័យទាំងឡាយដូចរៀបរាប់ខាងលើ។ នគរបាលបច្ចេកទេសវិទ្យាសាស្ត្រខេត្តពោធិសាត់បានធ្វើការត្រួតពិនិត្យស្នាមត្រាលើរូបថតដែលបានបិទ ក្នុងលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតបានលទ្ធផលថា ពិតជាមានស្នាមត្រានៅលើរូបថតប្រាកដមែន ២-បណ្តឹងតវ៉ា ឬបណ្តឹងជំទាស់អំពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬជនបរទេសមានឈ្មោះក្នុងបញ្ជីបោះឆ្នោតត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

បណ្តឹងនេះផុតអាជ្ញាយុកាលតាំងពីចុងឆ្នាំ២០១២ ម្លេះ ៣-ករណីលោក **ផាន់ វណ្ណសិទ្ធិ** មានភរិយាជាបេក្ខជនតំណាងរាស្ត្រមណ្ឌលខេត្តពោធិសាត់ និងលោក **ឯម ភ្វីបុទ្ធិ** មានបងស្រីជាបេក្ខជនតំណាងរាស្ត្រមណ្ឌលខេត្តពោធិសាត់នោះ មិនប៉ះពាល់ដល់ទំនាស់ផលប្រយោជន៏ក្នុងការងាររៀបចំការបោះឆ្នោតទេ ៤-ទឡ្ហីករណ៏ ដែលដើមបណ្តឹងសំអាងទាំងប៉ុន្មាន ពុំមានលក្ខណៈត្រឹមត្រូវតាមបទប្បញ្ញត្តិ មាត្រា ១១១ ថ្មី និងមាត្រា ១១២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនាំឱ្យមានការរៀបចំការបោះឆ្នោតសាជាថ្មីទេ ៥-ដើមបណ្តឹងមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីគណៈកម្មការ និងសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារឬភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា នៅមណ្ឌលខេត្តពោធិសាត់សរុបមាន ៦២៥ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៧២,៦០ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

សម្រេច

មាត្រា ១. ទទួលពាក្យបណ្តឹងរបស់លោក **ងឹម ញៀង** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២. តម្កល់លិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣. សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ 235/039/2013
ថ្ងៃ 18 សីហា 2013
ម៉ោង 10:50

ពាក្យបណ្ដឹងតវ៉ា

ខ្ញុំបាទឈ្មោះ **ខឹម ញ៉េខ** អាយុ៣៩ឆ្នាំ ជាតំណាងគណបក្សសង្គ្រោះជាតិ មានទីលំនៅផ្ទះលេខ១២ ផ្លូវលេខ៣១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សូមគោរពចូលមក
ឯកឧត្ដមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ: ប្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តពោធិសាត់។

យោង: - លិខិតលេខ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត។
- ពាក្យបណ្ដឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្ដម សម រង្ស៊ី។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្ដមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទ បានដាក់ពាក្យបណ្ដឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ៖

១. ទាមទារបដិសេធលទ្ធផលនេះការបោះឆ្នោតនៅមណ្ឌលពោធិសាត់។

២. ទាមទារឲ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តពោធិសាត់ឡើងវិញ។

៣. ទាមទារឲ្យបោះឆ្នោតឡើងវិញទូទាំងខេត្តពោធិសាត់។

ខ្ញុំបាទទាមទារយ៉ាងនេះដោយសំអាងថា:

១. នៅមណ្ឌលខេត្តពោធិសាត់ទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុច្បាស់លាស់។

២. នៅការិយាល័យមួយចំនួន ប្រធានការិយាល័យបោះឆ្នោតបានអនុញ្ញាតិអោយអ្នកកាន់ លិខិតបញ្ជាក់អត្តសញ្ញាណមិនត្រឹមត្រូវបោះឆ្នោត ហើយខ្ញុំបាទ បានប្ដឹងបដិសេធលទ្ធផលបោះឆ្នោតតាមឋានានុក្រមរួចហើយ តែត្រូវគណៈកម្មាធិការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់បដិសេធ។

៣.ករណីទំនាស់ផលប្រយោជន៍រវាងគណៈកម្មាការរៀបចំការបោះឆ្នោតខេត្តពោធិសាត់ និងបេក្ខជនតំណាងរាស្ត្ររបស់គណបក្សនយោបាយ។

៤. ករណីមានឈ្មោះជនបរទេសច្រើននៅក្នុងបញ្ជីបោះឆ្នោត។

ក្រោយពីបានដាក់ពាក្យបណ្ដឹងមក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចបដិសេធពាក្យបណ្ដឹងរបស់ខ្ញុំបាទ។

ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្ដឹងរបស់ខ្ញុំចោលនេះទេ។

អាស្រ័យហេតុនេះ សូមឯកឧត្ដមប្រធាន មេត្តាទទួលយកនូវពាក្យបណ្ដឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្ដីអនុគ្រោះ។

សូមឯកឧត្ដមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខៈ៧១៥/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

សូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល

កម្មវត្ថុ : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣៥/០១០/២០១៣ កបធ.ច
ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

យោង : មាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៣០ នាទី ក្រុមប្រឹក្សា-ធម្មនុញ្ញបានពិនិត្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ហូរ វ៉ាន់** តំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលរាជធានីភ្នំពេញ និង បានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

អគ្គលេខាធិការ

ចាន់ រ៉ាស៊ី

អាគារសវិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១. E-mail: sgccc@online.com/ info@ccc.gov.kh, Website :http://www.ccc.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ២៣២/០៣៦/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

សេចក្តីសម្រេច

លេខ : ១៣៥/០១០/២០១៣ កបធ.ច

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ហូរ ទាវ៉ន់** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលរាជធានីភ្នំពេញ
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **ហូរ ទាវ៉ន់** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលរាជធានីភ្នំពេញ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៨១/១៣ គ.ជ.ប ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ហូរ ទាវ៉ន់** កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយភស្តុតាងជាឯកសារ ស៊ីឌី និង ឌីវីឌី ដាក់ក្នុង ០៣ កេសក្រដាស និងក្នុងកញ្ចប់ក្រដាស ០១
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ហូរ ទាវ៉ន់** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៥ និង ៣០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់ឯកឧត្តម **ហូរ ទៀន់** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តមបានបញ្ជាក់ការទាមទារដូចតទៅ ÷ ១-ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះអ្នកដែលបាត់ឈ្មោះទាំងអស់ឡើងវិញ និង បានបោះឆ្នោតឡើងវិញ ២-ឱ្យបញ្ចេញបញ្ជីឈ្មោះដែលបានបោះឆ្នោតហើយផ្ទៀងផ្ទាត់ឈ្មោះស្ទួន ឈ្មោះខ្មោច (មានតែឈ្មោះតែមិនមានមនុស្ស) គ្រប់សង្កាត់ទាំងអស់ ៣-ឱ្យបោះឆ្នោតឡើងវិញនៅសង្កាត់ចំនួន ៣២ ដែលមានភាពមិនប្រក្រតីច្រើនជាងគេ ៤-កែតម្រូវឈ្មោះប្រជាពលរដ្ឋដែលខុស ហើយឱ្យគាត់បានបោះឆ្នោតឡើងវិញ ៥-លុបឈ្មោះជនបរទេសទាំងអស់នៅក្នុងរាជធានីភ្នំពេញចោល មិនឱ្យជនបរទេសមានសិទ្ធិបោះឆ្នោត ៦-ផ្តន្ទាទោសអ្នកដែលមិនមានទីលំនៅនៅភ្នំពេញ បានមកបោះឆ្នោតនៅភ្នំពេញ។ ដើមបណ្តឹងទាមទារយ៉ាងនេះដោយសំអាងថា : ១-នៅមណ្ឌលរាជធានីភ្នំពេញទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោត។ គណបក្សសង្គ្រោះជាតិបានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋចំនួន ១.៥៤៧ នាក់ ២-នៅការិយាល័យជាច្រើនក្នុងរាជធានីភ្នំពេញមានឈ្មោះស្ទួនជាច្រើន ជាពិសេស នៅសង្កាត់បឹងកេងកង៣ សង្កាត់ផ្សារដើមថ្កូវ និងសង្កាត់ទន្លេបាសាក់ ក្នុងខណ្ឌចំការមន ៣-មានភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ នៅសង្កាត់កោះដាច់ សង្កាត់បឹងទំពុន ដែលក្នុងករណីនេះ គណបក្សសង្គ្រោះជាតិប្រមូលបានចំនួនប្រាំបី ៤-មានការកែឈ្មោះអ្នកបោះឆ្នោតជាច្រើន ៥-មានករណីបោះឆ្នោតជំនួសជាច្រើនដែលគណបក្សសង្គ្រោះជាតិបានទទួលបណ្តឹងពីប្រជាពលរដ្ឋចំនួនកៅសិបប្រាំ ៦-មានករណីមិនឱ្យប្រជាពលរដ្ឋបោះឆ្នោតជាច្រើននាក់ដែលគណបក្សសង្គ្រោះជាតិទទួលបានបណ្តឹងចំនួនសាមសិបពីរ ៧-មានជនបរទេសជាច្រើនមកបោះឆ្នោត ៨-មានអ្នកបោះឆ្នោតដែលមិនមានលំនៅស្ថាននៅរាជធានីបានទៅបោះឆ្នោត។ ជាចុងក្រោយឯកឧត្តម **ហូរ ទៀន់** បានសំណូមពរមកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីដោះស្រាយតាមនីតិវិធីដោយក្តីអនុគ្រោះ

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុតារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ បានបញ្ជាក់ថា : ១-ការប្តឹងតវ៉ា ឬជំទាស់ពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត ការកែឈ្មោះអ្នកបោះឆ្នោត និង មានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតនោះ ត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ បញ្ហានេះ ផ្អែកតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ គឺផុតអាជ្ញាយុកាលតវ៉ាហើយ។ ២-អំពីភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ការដែលថាមានអ្នកមកបោះឆ្នោតជំនួស ដើមបណ្តឹងពុំបានផ្តល់ភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ថា អ្នកកាន់លិខិតបញ្ជាក់អត្តសញ្ញាណទៅបោះឆ្នោតនៅការិយាល័យណាមួយទេ និងអ្នកបោះឆ្នោតជំនួស ក៏មិនដឹងថាបោះឆ្នោតនៅការិយាល័យណាមួយដែរ។

៣-ភស្តុតាងទាំងឡាយដែលបានផ្តល់ជូន មិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែលតម្រូវឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រៀបចំការបោះឆ្នោតសាជាថ្មីនៅ ៣១ សង្កាត់ នៃរាជធានីបានឡើយ (ក្នុងបណ្តឹងតវ៉ាមកក្រុមប្រឹក្សាធម្មនុញ្ញឯកឧត្តម **ហូរ ទ៉ាន់** បន្ថែមឱ្យបោះឆ្នោតសាជាថ្មី ០១ សង្កាត់ទៀត)។ ៤-ដើមបណ្តឹងមិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលរាជធានីភ្នំពេញសរុបមាន ១.៦៩០ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៦៦,៤៦ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

សម្រេច

មាត្រា ១.- ទទួលពាក្យបណ្តឹងរបស់ឯកឧត្តម **ហូរ ទ៉ាន់** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

មាត្រា ២.- តម្កល់លិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

មាត្រា ៣.- សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ...222/036/2013...
ថ្ងៃ...14.សីហា.2013...
បញ្ជូន...15.30.

ពាក្យបណ្តឹងតវ៉ា

ខ្ញុំបាទឈ្មោះ **ហួរ ម៉ាន់** អាយុ៦៦ឆ្នាំ ជាតំណាងគណបក្សសង្គ្រោះជាតិ មានទីលំនៅផ្ទះលេខ១៩A ផ្លូវលេខ៥៩៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

សូមគោរពចូលមក

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ: ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលរាជធានីភ្នំពេញ។

យោង: - លិខិតលេខ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

- ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម សម រង្ស៊ី។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទ បានដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាមទារ:

១. ទាមទារឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះអ្នកដែលបាត់ឈ្មោះទាំងអស់ឡើងវិញ និងបានបោះឆ្នោតឡើងវិញ។

២. ទាមទារឲ្យបញ្ចេញបញ្ជីឈ្មោះដែលបានបោះឆ្នោតហើយ ផ្ទៀងផ្ទាត់ឈ្មោះស្ទួន ឈ្មោះខ្មោច(មានតែឈ្មោះតែមិនមានមនុស្ស) គ្រប់សង្កាត់ទាំងអស់ទូទាំងរាជធានីភ្នំពេញ។

៣. ទាមទារឲ្យបោះឆ្នោតឡើងវិញនៅសង្កាត់ចំនួន៣២ទូទាំងរាជធានីភ្នំពេញ ដែលមានភាពមិនប្រក្រតីច្រើនជាងគេ។

៤. កែតម្រូវឈ្មោះប្រជាពលរដ្ឋដែលខុស ហើយឲ្យគាត់បានបោះឆ្នោតឡើងវិញ។

៥. លុបឈ្មោះជនបរទេសទាំងអស់នៅរាជធានីភ្នំពេញចោល មិនឲ្យជនបរទេសមានសិទ្ធិបោះឆ្នោត។

៦. ផ្តន្ទាទោសអ្នកដែលមិនមានទីលំនៅ នៅភ្នំពេញ បានមកបន្លំបោះឆ្នោតនៅភ្នំពេញ។

ខ្ញុំបាទទាមទារយ៉ាងនេះដោយសំអាងថា:

១. នៅមណ្ឌលរាជធានីភ្នំពេញទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោត។ គណបក្សសង្គ្រោះជាតិ ទទួលបានពាក្យបណ្តឹងពីប្រជាពលរដ្ឋចំនួន១៥៤៧នាក់។

២. នៅការិយាល័យជាច្រើនក្នុងរាជធានីភ្នំពេញមានឈ្មោះស្ទួនជាច្រើន ជាពិសេសគឺនៅ៣សង្កាត់ សង្កាត់បឹងកេងកង៣, សង្កាត់ផ្សារដើមថ្កូវ និងសង្កាត់ទន្លេបាសាក់ ក្នុងខណ្ឌចំការមន។

៣. មានភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ គឺនៅសង្កាត់កោះដាច់ សង្កាត់បឹងទំពន់ ដែលក្នុងករណីនេះគណបក្សសង្គ្រោះជាតិប្រមូលបានចំនួន៨ករណី។

៤. មានការកែឈ្មោះអ្នកបោះឆ្នោតជាច្រើននៅរាជធានីភ្នំពេញ។

៥. មានករណីបោះជំនួសជាច្រើននៅរាជធានីភ្នំពេញ។ គណបក្សសង្គ្រោះជាតិទទួលបានពាក្យបណ្តឹងពីប្រជាពលរដ្ឋចំនួន៩៥ករណី។

៦. មានករណីមិនឲ្យប្រជាពលរដ្ឋបោះឆ្នោតជាច្រើននៅរាជធានីភ្នំពេញ។ គណបក្សសង្គ្រោះជាតិទទួលបានបណ្តឹងចំនួន៣២ករណី។

៧. មានជនបរទេសជាច្រើនមកបោះឆ្នោតនៅរាជធានីភ្នំពេញ។

៨. មានអ្នកបោះឆ្នោតដែលមិនមានលំនៅដ្ឋាននៅរាជធានីភ្នំពេញ មកបោះឆ្នោតនៅរាជធានីភ្នំពេញ។

ក្រោយពីបានដាក់ពាក្យបណ្តឹងមក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំ។

ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលនេះទេ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាទទួលយកនូវពាក្យបណ្តឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

ហត្ថលេខា

<u>សូមជូនភ្ជាប់មកជាមួយនូវឯកសារថតចម្លង</u>

- *លិខិតលេខ៨២៣/១៣* *ចំនួន០១ច្បាប់។*
- *ពាក្យបណ្តឹង* *ចំនួន០១ច្បាប់។*
- *លិខិតផ្ទេរសិទ្ធិ* *ចំនួន០១ច្បាប់។*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខៈ ១៤០ /២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

សូមគោរពជូន
ឯកឧត្ដមអគ្គលេខាធិការរាជរដ្ឋាភិបាល

កម្មវត្ថុ : សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣៦/០១១/២០១៣ កបធ.ច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

យោង : មាត្រា ៣៤ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្ដមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យបណ្ដឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ដែលប្ដឹងជំទាស់លទ្ធផលឆ្នោតបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ នីតិកាលទី៥ ឆ្នាំ២០១៣ និងបានចេញជាសេចក្ដីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្ដមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្ដមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

អគ្គលេខាធិការ

ចាន់ រ៉ាស៊ី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ២២៨/០៣២/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

សេចក្តីសម្រេច

លេខ : ១៣៦/០១១/២០១៣ កបធ.ច

ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តបន្ទាយមានជ័យ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **រស់ សួ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តបន្ទាយមានជ័យ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៧១/១៣ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **រស់ សួ** កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៤៥ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សា-ធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោក **រស់ សួ** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារ ដូចតទៅ ÷ ១-បញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ មានខុសឈ្មោះ និង ឈ្មោះស្ទួនច្រើន ២-បាត់ឈ្មោះអ្នកបោះឆ្នោត ៣-អ្នកបោះឆ្នោត បោះឆ្នោតជំនួសឈ្មោះគេ ៤-ទឹកខ្មៅលុបមិនជ្រះ ៥-លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត គ្មានរូបថត និង ត្រា និង ៦-ផ្ទៀងផ្ទាត់លទ្ធផលឆ្នោតបណ្តោះអាសន្នតាមទម្រង់ ១១០៤ ឡើងវិញ។ ដើមបណ្តឹងបានបញ្ជាក់បន្ថែមថា នៅកន្លែងបោះឆ្នោតក្នុងខេត្តបន្ទាយមានជ័យ មានសុវត្ថិភាពទាំងអស់ គ្មានបញ្ហាអ្វីទេ គ្មានអំពើហិង្សាទេ គឺមានតែបញ្ហាបាត់ឈ្មោះតែប៉ុណ្ណោះ ហើយលោកពុំមានភស្តុតាងអ្វីប្រគល់ជូនក្រុមប្រឹក្សាធម្មនុញ្ញទេ។ លោក **រស់ សួ** សំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ និងពិចារណាឡើងវិញ នូវសេចក្តីសម្រេច (តាមពិតជាលិខិត) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ បានបញ្ជាក់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបដិសេធពាក្យបណ្តឹងរបស់លោក **រស់ សួ** តាមលិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ ដោយសំអាងហេតុផលដូចតទៅ ÷ ១-ដើមបណ្តឹងគ្រាន់តែរៀបរាប់អំពីភាពមិនប្រក្រតី ប៉ុន្តែខ្លួនគាត់ក៏មិនច្បាស់លាស់ខ្លួនឯងផង ២-លោក **រស់ សួ** បញ្ជាក់ថាគាត់គ្មានភស្តុតាងទេ និង ៣-អ្នកសង្កេតការណ៍តំណាងគណបក្សសង្គ្រោះជាតិ បានចុះហត្ថលេខាលើកំណត់ហេតុនៅគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងមណ្ឌលខេត្តបន្ទាយមានជ័យរួចអស់ហើយ។ ទន្ទឹមនឹងនេះ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធចំណុចទី៦ ចែងក្នុងពាក្យបណ្តឹងជំទាស់ ដោយហេតុថា ពុំមានក្នុងពាក្យបណ្តឹងនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ ។ រីឯការប្តឹងតវ៉ា ឬ ប្តឹងជំទាស់នឹងបញ្ជីឈ្មោះបោះឆ្នោត និង ការចុះឈ្មោះបោះឆ្នោត បានផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២ ម៉្លេះ ។ ដើមបណ្តឹងមិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិក គណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬ ភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិ នៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ
- យល់ឃើញថា នៅមណ្ឌលខេត្តបន្ទាយមានជ័យសរុបមាន ៩៦២ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៥៤,១៦ ភាគរយ

- យល់ឃើញថា លិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

សម្រេច

មាត្រា ១.- ទទួលពាក្យបណ្តឹងរបស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២.- តម្កល់លិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ 228/032/2013
ថ្ងៃ 14 សីហា 2013
ម៉ោង 2:45 រសៀល

ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ **រស់ សួ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ ៖ សុំប្តឹងជំទាស់លទ្ធផលឆ្នោតបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ ។

យោង ៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ

-បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥

-លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់លោក **សម រង្ស៊ី** ផ្ទេរសិទ្ធិជូន លោក **រស់ សួ**

-ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ខេត្តបន្ទាយមានជ័យ

-សេចក្តីសម្រេចលេខ៖៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទបានដាក់ពាក្យបណ្តឹងតវ៉ា ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ទាមទារ ៖

១- បញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ ខុសឈ្មោះ និងឈ្មោះស្ទួនច្រើន

២- បាត់ឈ្មោះ អ្នកបោះឆ្នោត

៣- អ្នកបោះឆ្នោត បោះឆ្នោតជំនួសឈ្មោះគេ

៤- ទឹកខ្មៅលុបមិនជ្រះ

៥- លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត ដោយគ្មានរូបថត និងត្រា

៦- ផ្ទៀងផ្ទាត់លទ្ធផលឆ្នោតបណ្តោះអាសន្ន តាមទម្រង់១១០៤ ឡើងវិញ

សេចក្តីសម្រេចលេខ៖ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានបដិសេធបណ្តឹងតវ៉ា សុំទាមទារទាំង ៦ (ប្រាំមួយ) ចំណុចខាងលើ ដែលមានភាពមិនប្រក្រតី ទូទាំងខេត្តបន្ទាយមានជ័យ ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងពិចារណាឡើងវិញ នូវសេចក្តីសម្រេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ដែលផ្ទុយពីបទបញ្ជា និងនីតិវិធី ដែលច្បាប់បានកំណត់ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៣

ស្នាមមេដៃស្តាំ

រស់ សួ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាន

លេខ ៧៦១/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

សូមគោរពជូន

ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល

កម្មវត្ថុ : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣៧/០១២/២០១៣ កបធ.ច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

យោង : មាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋា-ភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់លោក **អ៊ុក ស៊ុយ** ដែលប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទម្រង់ ១១០២ និងទម្រង់ ១១០៤ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តតាកែវ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

អគ្គលេខាធិការ

ចាន់ វ៉ាស៊ី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ២៣៦/០៤០/២០១៣

ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣

សេចក្តីសម្រេច

លេខ : ១៣៧/០១២/២០១៣ កបធ.ច

ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **អ៊ុក ស៊ុយ** ប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទម្រង់ ១១០២ និងទម្រង់ ១១០៤ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តតាកែវ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **អ៊ុក ស៊ុយ** ធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តតាកែវ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៦២/១៣ គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **អ៊ុក ស៊ុយ** កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ និងឯកសារថតចម្លងមួយដុំមានចំនួនប៉ែតសិបប្រាំបួនសន្លឹក
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **អ៊ុក ស៊ុយ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១២ និង ២០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ នៃមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃបណ្តឹងរបស់លោក **អ៊ុក ស៊ុយ** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារដូចតទៅ ÷ ១-តវ៉ាឱ្យផ្ទៀងផ្ទាត់ឡើងវិញលើទម្រង់ ១១០២ និងទម្រង់ ១១០៤នៃមណ្ឌលខេត្តតាកែវទាំងអស់ ២-ទាមទារឱ្យផ្ទៀងផ្ទាត់នូវឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងខេត្តតាកែវឡើងវិញ ដោយហេតុថា ពលរដ្ឋមួយចំនួនមានឈ្មោះក្នុងឆ្នាំ២០១២ តែដល់ថ្ងៃបោះឆ្នោតឆ្នាំ២០១៣ បាត់ឈ្មោះពីបញ្ជីបោះឆ្នោត។ ពលរដ្ឋមួយចំនួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែត្រូវបានគេបោះឆ្នោតជំនួស ៣-មានពលរដ្ឋខុសឈ្មោះ ថ្ងៃខែឆ្នាំកំណើត ឬកាន់លិខិតបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតក្លែងក្លាយទៅបោះឆ្នោត អ្នកមិនទាន់គ្រប់អាយុទៅបោះឆ្នោតជំនួសលើឈ្មោះពលករដែលធ្វើការនៅក្រៅប្រទេស ឬឈ្មោះអ្នកដទៃទៀតបាន ដោយយករូបថតបិទលើលិខិតបញ្ជាក់អត្តសញ្ញាណរបស់ពលករនៅក្រៅប្រទេស រួចជនមិនទាន់គ្រប់អាយុនោះទៅបោះឆ្នោតបានតែម្តង និង ៤-ទឹកខ្មៅជ្រលក់ដៃលុបលាងជ្រះ។ អនុភូមិតាសួនបានយកទឹកខ្មៅឱ្យឈ្មោះ កា ផាត ជ្រលក់ដៃមុនថ្ងៃបោះឆ្នោត លួងលោមឱ្យជាប្រាក់ទិញទឹកចិត្តចំនួន ៥០.០០០ រៀល។ ដើមបណ្តឹងបានអះអាងថា មានសាក្សី និងភស្តុតាងជាច្រើនទៀត តែចាំបង្ហាញនៅក្នុងសវនាការជាសាធារណៈនៅក្រុមប្រឹក្សាធម្មនុញ្ញ។ ពេលជួបក្រុមទី៣ លោកផ្តល់ជូនឯកសារថតចម្លងមួយចំនួនប៉ុណ្ណោះ តែក្រុមទី៣ ពិនិត្យទៅឃើញថាមិនពេញលក្ខណៈអាចយកមកពិចារណាបានទេ

- យល់ឃើញថា ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ បានបញ្ជាក់ថា ÷ ការប្តឹងតវ៉ាពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះ ត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត រឿងនេះបានផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២មកម្ល៉េះ។ រីឯរឿងផ្សេងទៀតដែលដើមបណ្តឹងបានលើកឡើងតាមពិតត្រូវបានដោះស្រាយតាមលំដាប់លំដោយរហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញចប់សព្វគ្រប់ហើយ

- យល់ឃើញថា ដើមបណ្តឹងធ្វើសំណូមពរដោយទទូចឱ្យក្រុមប្រឹក្សាធម្មនុញ្ញបើកសវនាការជាសាធារណៈនោះ តាមការពិតសាមីខ្លួនពុំមានទឡ្ហីករណ៍សមហេតុផលដូចមានចែងក្នុងវាក្យខណ្ឌទី៥ នៃមាត្រា១១៧ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា នៅមណ្ឌលខេត្តតាកែវសរុបមាន ១.៣០២ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៧៨,៤១ ភាគរយ

- យល់ឃើញថា លិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

សម្រេច

មាត្រា ១.- ទទួលពាក្យបណ្តឹងរបស់លោក **អ៊ុក ស៊ុយ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២.- តម្កល់លិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ. 236/04.01/2013
ថ្ងៃ. 19. សីហា 2013
បញ្ជូនទៅ .ន.វ.ទ.ល.

ពាក្យបណ្តឹងតវ៉ា

ខ្ញុំបាទឈ្មោះ អ៊ុក ស៊ុយ ឆ្នាំកំណើត១៩៧២ ជាតំណាងគណបក្សសង្គ្រោះជាតិ មានទីលំនៅ ភូមិវាល ឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ។

សូមគោរពចូលមក
ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ៖ ប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទម្រង់១១០២ និង ទម្រង់១១០៤ នៃការបោះឆ្នោតជ្រើសរើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តតាកែវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

យោង៖ -លិខិតលេខ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

-លិខិតផ្ទេរ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣របស់ឯកឧត្តម សម រង្ស៊ី។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនឯកឧត្តមប្រធានជ្រាបថា៖ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទបានដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មារជាតិរៀបចំការបោះឆ្នោត តវ៉ា នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដែលប្រកាសដោយគ.ជ.ប កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ គឺទាមទារ៖

១-តវ៉ាឲ្យផ្ទៀតផ្ទាត់ឡើងវិញលើទម្រង់១១០២ និងទម្រង់១១០៤នៃមណ្ឌលខេត្តតាកែវទាំងអស់ ។

២-ទាមទាឲ្យផ្ទៀងផ្ទាត់នូវឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតក្នុងខេត្តតាកែវឡើងវិញដោយហេតុថា៖

- ពលរដ្ឋមួយចំនួន មានឈ្មោះក្នុងឆ្នាំ២០១២ (ក្រោយពីធ្វើបញ្ជីបច្ចុប្បន្នភាព ឆ្នាំ២០១២មក) តែដល់ថ្ងៃបោះឆ្នោតឆ្នាំ២០១៣ បាត់ឈ្មោះពី បញ្ជីអ្នកបោះឆ្នោត។
- ពលរដ្ឋមួយចំនួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែត្រូវបានគេបោះឆ្នោតជំនួស (ដូចជានៅការិយាល័យ០៥៦០ ឈ្មោះ ហ៊ី សុខណា បោះឆ្នោតជំនួសឈ្មោះ ពេជ្រ ស៊ីណា, នៅការិយាល័យ ០៣៧១ ឈ្មោះ សុខ ចន្ទី ត្រូវបានគេបោះឆ្នោតជំនួស និងឈ្មោះ ម៉ោង ឈឿន ត្រូវបានគេបោះជំនួស។ករណីទាំងនេះ មានច្រើនស្ទើរគ្រប់ការិយាល័យបោះឆ្នោតទូទាំងខេត្ត។

៣-មានពលរដ្ឋខុសឈ្មោះ ថ្ងៃខែឆ្នាំកំណើត ឬកាន់លិខិតបញ្ជាក់អត្តសញ្ញាណប័ណ្ណបំពើឲ្យការបោះឆ្នោតក្លែងក្លាយទៅបោះឆ្នោតបានមានន័យថា៖

- អ្នកមិនទាន់គ្រប់អាយុទៅបោះឆ្នោតជំនួសលើឈ្មោះពលករដែលធ្វើការនៅក្រៅប្រទេស ឬ ឈ្មោះអ្នកដទៃទៀតបានដោយយកឲ្យបចតបិទលើលិខិតបញ្ជាក់អត្តសញ្ញាណរបស់ពលករនៅក្រៅប្រទេស អ្នកដទៃទៀត រួចជនមិនគ្រប់អាយុនោះទៅបោះឆ្នោតបានតែម្តង(ជាក់ស្តែងនៅការិយាល័យលេខ០៥៧៣ ការិយាល័យលេខ១០៩២និងមានកូនមេភូមិឈ្មោះ ឡុង ហាម ជាអ្នកបានប្រព្រឹត្ត)។

៩-ទឹកខ្មៅជ្រលក់ដៃលុបលាងជ្រះ (ជាករណីបន្លំសន្លឹកឆ្នោត និង រំលោភសិទ្ធិដល់អ្នកបោះឆ្នោតដោយសារបុគ្គលដែលបំណងខូចនោះទៅបោះឆ្នោតបានច្រើនដង ជាក់ស្តែងកូនអនុភូមិព្រៃផ្តៅ បោះឆ្នោតបានចំនួន០២ដងនៅការិយាល័យលេខ ១១៥៧។

- អនុមេភូមិតាសួន បានយកទឹកខ្មៅឲ្យឈ្មោះ កា ជាត ជ្រលក់ដៃមុនថ្ងៃបោះឆ្នោត លួងលោមឲ្យជាប្រាក់ទិញទឹកចិត្តចំនួន៥០០០០រៀល(ករណីនេះជាការរំលោភសិទ្ធិដល់ការបោះឆ្នោតយ៉ាងធ្ងន់ធ្ងរ ដើម្បីបំបាត់សម្លេងគាំទ្រដែលជាលទ្ធផលដល់បក្សសង្គ្រោះជាតិ)។

ក្រោយពីបានដាក់ពាក្យបណ្តឹងទៅគ.ជ.ប មក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោតបានសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំ។

ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំបាទចោលនេះទេ។

សំណូមពរ៖ ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញ បើកសវនាការ ជាសាធារណៈតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅចំណុចក-៤-២ ស្តីពីការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញត្រង់ប្រការ១១-៩-៣៨។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាទទួលយកនូវពាក្យបណ្តឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ធ្វើនៅ,ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

ហត្ថលេខា

អ៊ុក ស៊ុយ

<u>សូមជូនភ្ជាប់មកជាមួយនូវឯកសារថតចម្លង</u>

-លិខិតលេខ៨២៦/១៣ ចំនួន០១ច្បាប់។

-លិខិតផ្ទេរសិទ្ធិ ចំនួន០១ច្បាប់។

-ស្នាមមេដៃអ្នកបាត់ឈ្មោះ អ្នកគេបោះឆ្នោតជំនួសចំនួន ០១ច្បាប់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាន

លេខ: ១៦៦ /២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

សូមគោរពជូន

ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល

កម្មវត្ថុ : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣៨/០១៣/២០១៣ កបធ.ច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

យោង : មាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **រស់ ស្វ** ដែលប្តឹងជំទាស់លទ្ធផលឆ្នោតបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ និងបានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

អគ្គលេខាធិការ

ចាន់ រីស៊ី

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១. E-mail: sgccc@online.com/ info@ccc.gov.kh, Website :http://www.ccc.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ២២៩/០៣៣/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

សេចក្តីសម្រេច

លេខ : ១៣៨/០១៣/២០១៣ កបធ.ច

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្ដឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្ដឹងជំទាស់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តស្វាយរៀង
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្ដម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **រស់ សួ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្ដឹងតវ៉ាទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តស្វាយរៀង
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៧២/១៣ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **រស់ សួ** កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្ដម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ ។

ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្ដឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៤៥ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ម៉ោង បន្ទាប់ពីទទួលលិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ មាត្រា ២៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះក្រុមប្រឹក្សា-ធម្មនុញ្ញអាចទទួលយកបណ្ដឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្ដឹងរបស់លោក **រស់ សួ** ប្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការបំភ្លឺចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារដូចតទៅ ÷ ១-ប្រជាពលរដ្ឋបាត់ឈ្មោះពីបញ្ជីអ្នកបោះឆ្នោត ២-មានការបោះឆ្នោតជំនួស ៣-មានឈ្មោះខុសច្រើន ៤-ទឹក

ខ្មៅលុបមិនជ្រះ ៥-លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត គ្មានរូបថត និង ត្រា និង ៦-ផ្ទៀងផ្ទាត់លទ្ធផលឆ្នោតបណ្ដោះអាសន្នស្រុកចន្ទ្រា ក្រុងបាវិត តាមទម្រង់១១០៤ ឡើងវិញ ។ ដើមបណ្ដឹងបានបញ្ជាក់បន្ថែមថា ក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១២ មានការបាត់ឈ្មោះអ្នកបោះឆ្នោតច្រើន បើប្រៀបធៀបទៅនឹងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ១៩៩៨ ។ ចំពោះថ្ងៃបោះឆ្នោតនៅស្រុកចន្ទ្រា និង ក្រុងបាវិត មិនមានការគម្រាមកំហែង មិនមានអំពើហិង្សា និង មិនមានការបាញ់បោះទេ ប៉ុន្តែគេប្រើសង្គ្រាមចិត្តសាស្ត្រ ដោយសារប្រជាពលរដ្ឋនៅទីនោះមានចំណេះដឹងទាប ។ ចំពោះបន្ទប់បោះឆ្នោតពិតជាសម្ងាត់ និង មិនមានចលាចលទេនៅថ្ងៃបោះឆ្នោត ប៉ុន្តែពេលរាប់សន្លឹកឆ្នោតមានការបិទទ្វារបង្អួចនៅការិយាល័យមួយ តែបន្ទាប់ពីយើងធ្វើការតវ៉ា ១៥នាទីក្រោយមកគេក៏បើកវិញ ។ ជាទូទៅនៅការិយាល័យបោះឆ្នោតខេត្តស្វាយរៀង មានសុវត្ថិភាពទាំងអស់ គ្មានបញ្ហាអ្វីទេ គ្មានអំពើហិង្សា គឺមានតែបញ្ហាបាត់ឈ្មោះតែប៉ុណ្ណោះ។ ដើមបណ្ដឹងសំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ និង ពិចារណាឡើងវិញនូវលិខិតជូនដំណឹងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង សូមឱ្យកែតម្រូវបញ្ជីបោះឆ្នោតដែលខុសកន្លងមក និង សូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យលទ្ធភាពកែច្បាប់បោះឆ្នោត និង មុនពេលបោះឆ្នោត សូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញអញ្ជើញគ្រប់គណបក្សនយោបាយមកណែនាំរឿងបោះឆ្នោតដើម្បីឱ្យគោរពទាំងអស់គ្នា

-យល់ឃើញថា ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបំភ្លឺចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ បានបញ្ជាក់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបដិសេធពាក្យបណ្ដឹងរបស់លោក **រស់ សូ** តាមលិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ដោយសំអាងហេតុផលដូចតទៅ ÷ ១-ដើមបណ្ដឹងពុំមានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីនីមួយៗ ២-ការបាត់ឈ្មោះ ឬមានឈ្មោះលើសពីមួយក្នុងបញ្ជី ឬឈ្មោះស្ទួន និង ខុសឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺត្រូវប្ដឹងតវ៉ា ឬប្ដឹងជំទាស់នៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំស្របតាមមាត្រា ៤៩ថ្មី(បី) និងចាប់ពីមាត្រា ៥៧ថ្មី រហូតដល់មាត្រា ៦៨ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ ៣-ដើមបណ្ដឹងពុំមានភស្តុតាងដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និង អាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ដែលកើតមានឡើងនៅស្រុកចន្ទ្រា និង ក្រុងបាវិត ដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៤-ដើមបណ្ដឹងពុំមានភស្តុតាងបញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា ១១១ ថ្មី និង មាត្រា ១១២ ថ្មី នៃច្បាប់ស្ដីពី

វិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលអាចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើការបោះឆ្នោតសាជាថ្មីនៅស្រុកចន្ទ្រា និង ក្រុងបាវិត បានឡើយ ។ ទន្ទឹមនឹងនេះ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធចំណុចទី៦ ដែលចែងក្នុងពាក្យបណ្ដឹងជំទាស់ដោយសំអាងថា ពុំមានក្នុងពាក្យបណ្ដឹងនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ

- យល់ឃើញថា នៅមណ្ឌលខេត្តស្វាយរៀងសរុបមាន ៧៨៣ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៧៥,៥៨ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

សម្រេច

មាត្រា ១.- ទទួលពាក្យបណ្ដឹងរបស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

មាត្រា ២.- តម្កល់លិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

មាត្រា ៣.- សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ...
ថ្ងៃ...
បញ្ជូន...

ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ **រស់ សួ** ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សូមគោរពជូន
ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ ៖ សុំប្តឹងជំទាស់លទ្ធផលឆ្នោតបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ ។

យោង ៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ

-បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥

-លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់លោក **សម រង្ស៊ី** ផ្ទេរសិទ្ធិជូន លោក **រស់ សួ**

-ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ខេត្តស្វាយរៀង

-សេចក្តីសម្រេចលេខ៖៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទបានដាក់ពាក្យបណ្តឹងតវ៉ា ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ទាមទារ ៖

១- បាត់ឈ្មោះ អ្នកបោះឆ្នោត

២- អ្នកបោះឆ្នោត បោះឆ្នោតជំនួសឈ្មោះគេ

៣- បញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ ខុសឈ្មោះ និងឈ្មោះស្ទួនច្រើន

៤- ទឹកខ្មៅលុបមិនជ្រះ

៥- លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត គ្មានរូបថត និងត្រា

៦- ផ្ទៀងផ្ទាត់លទ្ធផលឆ្នោតបណ្តោះអាសន្ន ស្រុកចន្ទ្រា ក្រុងបាវិត តាមទម្រង់១១០៥ ឡើងវិញ

សេចក្តីសម្រេចលេខ៖ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានបដិសេធបណ្តឹងតវ៉ា សុំទាមទារទាំង ៦ (ប្រាំមួយ) ចំណុចខាងលើ ដែលមានភាពមិនប្រក្រតី ទូទាំងខេត្តស្វាយរៀង ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងពិចារណាឡើងវិញ នូវសេចក្តីសម្រេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ដែលផ្ទុយពីបទបញ្ជា និងនីតិវិធី ដែលច្បាប់បានកំណត់ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ៕

រាជធានីភ្នំពេញ,ថ្ងៃទី...១៧...ខែសីហា ឆ្នាំ២០១៣

ស្នាមមេដៃស្តាំ

រស់ សួ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៥៩ អនក្រ-បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០២៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋាន គយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១០១៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និង អនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១.-

ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៣៥០ ០០០ ០០០រៀល (បីរយហាសិបលានរៀលគត់) ពីជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) មកជំពូក ៦០ (ការទិញ) ជូនក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ។

មាត្រា២.-

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានទទួលស្គាល់ **សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ** (American University of Phnom Penh) សរសេរកាត់ជាភាសាខ្មែរ "ស.អ.ភ" និងសរសេរកាត់ជាភាសាអង់គ្លេស "AUPP"។

មាត្រា ២.-

សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ មានទីតាំងស្ថិតនៅអគារលេខ៥០ ផ្លូវលេខ៣១៥ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ស្ថិតនៅក្រោមឱវាទបច្ចេកទេស របស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៣.-

សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត លើមហាវិទ្យាល័យចំនួន៧ និងមជ្ឈមណ្ឌលចំនួន១ គឺ៖

១. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

២. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៣. មហាវិទ្យាល័យធុរកិច្ច និងសេដ្ឋកិច្ច

៤. មហាវិទ្យាល័យនីតិសាស្ត្រ

៥. មហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងការទូត

៦. មហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច

៧. មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្ម

៨. មជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ច

សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុនដំណើរការបណ្តុះបណ្តាល។ សាកលវិទ្យាល័យនេះ អាចបើកសាខា ឧបសម្ព័ន្ធ មហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតថ្មី ឬ ថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៤.-

សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ត្រូវរៀបចំក្រុមប្រឹក្សាភិបាលមួយ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

មាត្រា ៥.-

សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ និងធានាឲ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

-អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានា គុណភាពអប់រំ

-ត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន មកក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

មាត្រា ៦.-

និស្សិតសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ដែលបានរៀនចប់កម្មវិធីសិក្សា និងបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញ ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឲ្យដោយសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ បំពេញ និង អនុវត្តបាន តាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី និងគ្រប់ប្រធានស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមជាមួយសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអាមេរិកាំង ភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-សាលារាជធានីភ្នំពេញ

-ដូចមាត្រា ៧

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៧០ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ

សម្រេច

មាត្រា១.-

បំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការចលនាសប្បុរសជនចូលរួមកសាងព្រះវិហារ និងសមិទ្ធផលនានា ក្នុងវត្តសង្កែសាទប ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១-លោក **ជា ធឿន**

២-លោក **ឈន សារុន**

៣-លោក **ទ៉ាន់ ឆេងអ៊ាន់**

ខ-មេដាយប្រាក់ការងារ

-លោក **ជ័យ សារុន**

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៦១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការបញ្ជាការដ្ឋានវិស្វកម្ម នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា ១.-

បំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ចំនួន ២២២គ្រឿង ជូនកងឯកភាព នាយទាហាន នាយទាហានរង ពលទាហាន នៃបញ្ជាការដ្ឋានវិស្វកម្ម កងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ

ចំពោះអង្គភាព

០១- កងឯកភាព ផ្គត់ផ្គង់ទឹកនិងបន្សាបជាតិគីមីពុលលេខ៧៥ បញ្ជាការដ្ឋានវិស្វកម្ម

០២- កងឯកភាព ជាងជួសជុល

០៣- កងឯកភាព ឃ្លាំងគ្រឿងចក្រ

០៤- វរសេនាតូច ដឹកជញ្ជូនលេខ៧៩៦

០៥- ការិយាល័យ វិស្វកម្ម កងទ័ពជើងទឹក

០៦- វរសេនាតូច វិស្វកម្ម កងទ័ពជើងទឹក

០៧- ការិយាល័យ វិស្វកម្ម កងរាជអាវុធហត្ថលើផ្ទៃប្រទេស

០៨- ផ្នែកវិស្វកម្ម កងពលតូចទ័ពពិសេសឆ័ត្រយោងលេខ៩១១

០៩- កងអនុសេនាធំ វិស្វកម្មចំណុះកងពលតូចទ័ពពិសេសឆ័ត្រយោងលេខ៩១១

១០- ផ្នែកវិស្វកម្ម កងពលតូចលេខ៧០

១១- ផ្នែកវិស្វកម្ម កងពលតូចអន្តរាគមន៍លេខ១

១២- ផ្នែកវិស្វកម្ម បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការ

១៣- ផ្នែកវិស្វកម្ម កងពលតូចលេខ៤ ចំណុះកងពលធំអន្តរាគមន៍លេខ២

១៤- ផ្នែកវិស្វកម្ម កងពលតូចអលេខ៥ ចំណុះកងពលធំអន្តរាគមន៍លេខ២
១៥- ផ្នែកវិស្វកម្ម កងពលតូចលេខ៦ ចំណុះកងពលធំអន្តរាគមន៍លេខ២
១៦- ផ្នែកវិស្វកម្ម កងពលតូចលេខ៧ ចំណុះកងពលធំអន្តរាគមន៍លេខ៣
១៧- ផ្នែកវិស្វកម្ម កងពលតូចលេខ៨ ចំណុះកងពលធំអន្តរាគមន៍លេខ៣
១៨- ផ្នែកវិស្វកម្ម កងពលតូចលេខ៩ ចំណុះកងពលធំអន្តរាគមន៍លេខ៣
១៩- ផ្នែកវិស្វកម្ម កងពលតូចលេខ៤១ ចំណុះយោធភូមិភាគ៤
២០- ផ្នែកវិស្វកម្ម កងពលតូចលេខ៤២ ចំណុះយោធភូមិភាគ៤
២១- ការិយាល័យ វិស្វកម្ម យោធភូមិភាគ៥
២២- វរសេនាតូច វិស្វកម្ម យោធភូមិភាគ៥

ចំពោះបុគ្គល

០១-	ឧត្តមសេនីយ៍ត្រី	ជុំ ហុន	003451 នាយរងសេនាធិការបញ្ជាការដ្ឋានវិស្វកម្ម
០២-	វរសេនីយ៍ទោ	នង បូរ៉ា	014503 មេបញ្ជាការរង កងស្ពានបនាថ្នល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
០៣-	វរសេនីយ៍ត្រី	ខឹម កាន	027107 មេបញ្ជាការរង វរសេនាតូចដឹកជញ្ជូនលេខ៧៩៦ បញ្ជាការដ្ឋានវិស្វកម្ម
០៤-	វរសេនីយ៍ត្រី	គៀន សុផុន	049470 មេបញ្ជាការរង កងស្ពានបនាសំណង់អគារលេខ៧៣បញ្ជាការដ្ឋានវិស្វកម្ម
០៥-	វរសេនីយ៍ត្រី	ចាប សុផល	017724 ជំនួយការ ការិយាល័យសំណង់អគារ ស្នងការដ្ឋានភស្តុភារ បញ្ជាការដ្ឋានវិស្វកម្ម
០៦-	វរសេនីយ៍ត្រី	មូល សុផាណ្ណារិទ្ធ	009514 ជំនួយការ ការិយាល័យសំណង់អគារ ស្នងការដ្ឋានភស្តុភារ បញ្ជាការដ្ឋានវិស្វកម្ម
០៧-	វរសេនីយ៍ត្រី	វ៉ាន់ ឡេង	027221 ជំនួយការ ការិយាល័យសំណង់អគារ ស្នងការដ្ឋានភស្តុភារបញ្ជាការដ្ឋានវិស្វកម្ម
០៨-	វរសេនីយ៍ត្រី	រ៉ុង សាវ៉ាវី	017528 ជំនួយការ លេខាធិការដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម
០៩-	វរសេនីយ៍ត្រី	ប្រាក់ វទ្ធី	221358 ជំនួយការ ការិ.ល័យបុគ្គលិក ស្នងការដ្ឋានកសាងគ្រប់គ្រងកម្លាំង បញ្ជាការដ្ឋានវិស្វកម្ម
១០-	វរសេនីយ៍ត្រី	ហ៊ុល ជឿន	027292 ជំនួយការ ប្រតិបត្តិការ កងស្ពានបនាថ្នល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
១១-	វរសេនីយ៍ត្រី	ជុំ សាម៉េត	019345 ជំនួយការប្រតិបត្តិការ កងស្ពានបនាថ្នល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
១២-	វរសេនីយ៍ត្រី	ភឿក សំអាត	009560 មេបញ្ជាការ ក អ ធ ទី២ កងស្ពានបនាថ្នល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
១៣-	វរសេនីយ៍ត្រី	រត្ន័ សុភារ៉ា	049228 ជំនួយការ បុគ្គលិក កងឯកភាពស្ពានសាឡាងលេខ ៧១ បញ្ជាការដ្ឋានវិស្វកម្ម
១៤-	វរសេនីយ៍ត្រី	ទុំ ប៊ុនសំ	069258 ជំនួយការ ប្រតិបត្តិការ កងវត្ថុរាំងលេខ៧២ បញ្ជាការដ្ឋានវិស្វកម្ម
១៥-	វរសេនីយ៍ត្រី	ប៊ុន ចាន់ដារ៉ា	221403 ជំនួយការ បុគ្គលិក កងវត្ថុរាំងលេខ៧២ បញ្ជាការដ្ឋានវិស្វកម្ម
១៦-	វរសេនីយ៍ត្រី	កាក់ អ៊ាន	017677 ជំនួយការ ប្រតិបត្តិការ កងផ្គត់ផ្គង់ទឹកលេខ៧៥ បញ្ជាការដ្ឋានវិស្វកម្ម
១៧-	វរសេនីយ៍ត្រី	គីម សេងរិទ្ធី	017573 ជំនួយការភស្តុភារ កងស្ពានបនាថ្នល់លេខ៧១១ បញ្ជាការដ្ឋានវិស្វកម្ម
១៨-	វរសេនីយ៍ត្រី	សោម សុវណ្ណារ៉េត	017571 ជំនួយការហិរញ្ញវត្ថុ កងស្ពានបនាថ្នល់លេខ៧១១ បញ្ជាការដ្ឋានវិស្វកម្ម
១៩-	វរសេនីយ៍ត្រី	ដួង ចន្ថាន	221191 បើកបររថយន្តថ្នាក់ដឹកនាំបញ្ជាការបញ្ជាការដ្ឋានវិស្វកម្ម
២០-	វរសេនីយ៍ត្រី	ប៊ូ រតនា	009583 ជំនួយការថ្នល់ កងស្ពានបនាថ្នល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
២១-	វរសេនីយ៍ត្រី	សែម សារុធ	221389 ជំនួយការ ហិរញ្ញវត្ថុ កងវត្ថុរាំងលេខ៧២ បញ្ជាការដ្ឋានវិស្វកម្ម
២២-	វរសេនីយ៍ត្រី	ទុំ ចាន់ណារី	221375 ជំនួយការបច្ចេកទេស កងវត្ថុរាំងលេខ៧២ បញ្ជាការដ្ឋានវិស្វកម្ម
២៣-	វរសេនីយ៍ត្រី	ចាន់ ធឿន	221298 ជំនួការ ការិយាល័យប្រតិបត្តិការ បញ្ជាការដ្ឋានវិស្វកម្ម
២៤-	អនុសេនីយ៍ឯក	ជុំ សាវ៉ាត	017711 ជំនួយការ ថ្នល់ កងស្ពានបនាថ្នល់លេខ៧១៨ បញ្ជាការដ្ឋានវិស្វកម្ម
២៥-	អនុសេនីយ៍ឯក	បាន់ ដាឡែន	069392 ជំនួយការប្រេង ការិយាល័យភស្តុភារ ស្នងការដ្ឋានភស្តុភារ បញ្ជាការដ្ឋានវិស្វកម្ម
២៦-	អនុសេនីយ៍ឯក	ម៉ក់ សំណាង	049159 ជំនួយការស្បៀង ការិយាល័យភស្តុភារ ស្នងការដ្ឋានភស្តុភារ បញ្ជាការដ្ឋានវិស្វកម្ម
២៧-	អនុសេនីយ៍ឯក	អ៊ុំ សារ៉ន	043496 ជំនួយការ ការិយាល័យ ស្ពាន លូ ស្នងការដ្ឋានប្រតិបត្តិការវិស្វកម្ម បញ្ជាការដ្ឋានវិស្វកម្ម
២៨-	អនុសេនីយ៍ឯក	សេក វណ្ណារិទ្ធ	024452 នាយរងការិយាល័យ អចលនទ្រព្យ ស្នងការដ្ឋានភស្តុភារ បញ្ជាការដ្ឋានវិស្វកម្ម
២៩-	អនុសេនីយ៍ឯក	អ៊ុយ សុផាត	027253 មេបញ្ជាការ គ៣ កងស្ពានបនាថ្នល់លេខ៧១៨ បញ្ជាការដ្ឋានវិស្វកម្ម

៣០-	អនុសេនីយ៍ឯក	ជា ចាន់ផុល	059415 ជំនួយការ លេខាធិការដ្ឋានបញ្ជាការដ្ឋានវិស្វកម្ម
៣១-	អនុសេនីយ៍ឯក	ឈិន សុគន្ធ	040044 មេបញ្ជាការ គ៣ កងផ្គត់ផ្គង់ទឹកលេខ៧៥ បញ្ជាការដ្ឋានវិស្វកម្ម
៣២-	អនុសេនីយ៍ឯក	ឆេង សុផាន	059556 មេបញ្ជាការ គ៣ កងស្ថាបនាថ្នល់លេខ៧១៧ បញ្ជាការដ្ឋានវិស្វកម្ម
៣៣-	អនុសេនីយ៍ឯក	ផូ ចាន់ណាត	044130 ជំនួយការអប់រំចិត្តសាស្ត្រ កងស្ថាបនាស្ពានលេខ៧១៥ បញ្ជាការដ្ឋានវិស្វកម្ម
៣៤-	អនុសេនីយ៍ឯក	យត ជាហេង	039867 ជំនួយការបច្ចេកទេស កងស្ថាបនាថ្នល់លេខ៧១១ បញ្ជាការដ្ឋានវិស្វកម្ម
៣៥-	អនុសេនីយ៍ឯក	កង ជឿន	017663 ជំនួយការ អប់រំចិត្តសាស្ត្រ កងស្ថាបនាថ្នល់លេខ៧១៤ បញ្ជាការដ្ឋានវិស្វកម្ម
៣៦-	អនុសេនីយ៍ឯក	លី ព្រឿង	019349 មេបញ្ជាការ គ៣ កងស្ថាបនាថ្នល់លេខ៧១៤ បញ្ជាការដ្ឋានវិស្វកម្ម
៣៧-	អនុសេនីយ៍ឯក	ហៀវ ហ៊ិច	027223 ជំនួយការ ហិរញ្ញវត្ថុ កងស្ថាបនាថ្នល់លេខ៧១៤ បញ្ជាការដ្ឋានវិស្វកម្ម
៣៨-	អនុសេនីយ៍ឯក	ពត សាមី	049410 ជំនួយការបុគ្គលិក កងស្ថាបនាថ្នល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
៣៩-	អនុសេនីយ៍ឯក	យ៉ែម យឹម	042236 នាយផ្នែកវាស់ស្ទង់ កងស្ថាបនាថ្នល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
៤០-	អនុសេនីយ៍ទោ	ធឹង ពិត	221860 មេបញ្ជាការរង គ១កងស្ថាបនាថ្នល់លេខ៧១១ បញ្ជាការដ្ឋានវិស្វកម្ម
៤១-	អនុសេនីយ៍ទោ	ស៊ឹម ពឿន	049407 នាយផ្នែកវាស់ស្ទង់ កងស្ថាបនាថ្នល់លេខ៧១៧ បញ្ជាការដ្ឋានវិស្វកម្ម
៤២-	អនុសេនីយ៍ទោ	សាំង សុជាតិ	027271 ជំនួយការ ភូគព្ភសាស្ត្រ កងផ្គត់ផ្គង់ទឹកលេខ៧៥ បញ្ជាការដ្ឋានវិស្វកម្ម
៤៣-	អនុសេនីយ៍ទោ	ខាន់ ចាន់ស៊ី	069478 ជំនួយការបុគ្គលិក កងផ្គត់ផ្គង់ទឹកលេខ៧៥ បញ្ជាការដ្ឋានវិស្វកម្ម
៤៤-	អនុសេនីយ៍ទោ	សុខា ភុំ	027240 មេបញ្ជាការរង គ៤ កងស្ថាបនាថ្នល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
៤៥-	នាយចំណង់	លឹម កុសល	049352 បុគ្គលិក ដឹកជញ្ជូន កងស្ថាបនាថ្នល់លេខ៧១៧ បញ្ជាការដ្ឋានវិស្វកម្ម
៤៦-	ព្រិន្ទបាលទោ	អ៊ែ ស៊ីដែន	222091 នាយរងក្រុម កងស្ថាបនាថ្នល់លេខ៧១៧ បញ្ជាការដ្ឋានវិស្វកម្ម
៤៧-	វរសេនីយ៍ទោ	ធង សុវណ្ណារិទ្ធ	009245 នាយសេនាធិការរង ទទួលបន្ទុកវិស្វកម្ម កងពលតូចអន្តរាគមន៍លេខ១
១២-	ព្រិន្ទបាលឯក	**ខឹម ពិទូ**	049420 នាយក្រុម១ ខ១ គ១កងស្ពានថ្នល់លេខ៧១៤ បញ្ជាការដ្ឋានវិស្វកម្ម
១៣-	ព្រិន្ទបាលឯក	**កែប គីមឈីន**	222042 បុគ្គលិកភស្តុភារ កងស្ពានថ្នល់លេខ៧១៤ បញ្ជាការដ្ឋានវិស្វកម្ម
១៤-	ព្រិន្ទបាលឯក	**សឿង ប៊ិន**	069425 នាយក្រុម២ ខ១ គ៤កងស្ពានថ្នល់លេខ៧១៤ បញ្ជាការដ្ឋានវិស្វកម្ម
១៥-	ព្រិន្ទបាលឯក	**ឡុង សាយ**	221863 បុគ្គលិកដឹកជញ្ជូន កងឯកភាពលេខ៧៤ បញ្ជាការដ្ឋានវិស្វកម្ម
១៦-	ព្រិន្ទបាលឯក	**ឆន ទឹម**	221274 នាយក្រុម កងការពារបញ្ជាការដ្ឋានវិស្វកម្ម
១៧-	ព្រិន្ទបាលឯក	**នួន សុខុម**	079412 យុទ្ធជន កងការពារ បញ្ជាការដ្ឋានវិស្វកម្ម
១៨-	ព្រិន្ទបាលឯក	**ឃុន រដ្ឋា**	221142 ជាងជួសជុស ប្រពន្ធ័ខ្យល់ យានដ្ឋានបញ្ជាការដ្ឋានវិស្វកម្ម
១៩-	ព្រិន្ទបាលឯក	**ជិន សុផុត**	074119 នាយរងក្រុម២ ខ២ គ១ កងស្ពានថ្នល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
២០-	ព្រិន្ទបាលឯក	**ឃុត សុខ**	074140 បុគ្គលិកដឹកជញ្ជូន កងស្ពានថ្នល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
២១-	ព្រិន្ទបាលទោ	**សូ គុនថៃ**	222002 នាយរងក្រុម៣ ខ២ គ៣ កងឯកភាពលេខ៧៤ បញ្ជាការដ្ឋានវិស្វកម្ម

២២-	ព្រិន្ទបាលទោ	**អើក សុភាន់**	222074 មេបញ្ជាការ ខ១ គ២ កងស្ពានបាផ្តល់លេខ៧១៨ បញ្ជាការដ្ឋានវិស្វកម្ម
២៣-	ព្រិន្ទបាលទោ	**សេក វណ្ណា**	180239 នាយក្រុម៣ ខ២ គ៣ កងស្ពានបាសំណង់អគារលេខ៧៣ បញ្ជាការដ្ឋានវិស្វកម្ម
២៤-	ព្រិន្ទបាលទោ	**ថ្លាង រស់**	221975 មេបញ្ជាការ ខ៣ គ១ កងស្ពានបាសំណង់អគារលេខ៧៣ បញ្ជាការដ្ឋានវិស្វកម្ម
២៥-	ព្រិន្ទបាលទោ	**អ៊ីន សុភក្ត្រ័**	073814 មេបញ្ជាការ ខ១ គ១ កងស្ពានបាស្ពានលេខ៧១៥ បញ្ជាការដ្ឋានវិស្វកម្ម
២៦-	ព្រិន្ទបាលទោ	**សាន្ត សុផល**	054268 នាយក្រុម១ ខ៣ គ៣ កងស្ពានបាផ្តល់លេខ៧១១ បញ្ជាការដ្ឋានវិស្វកម្ម
២៧-	ពលបាលឯក	**ទេព ខុនណា**	082548 នាយក្រុម៣ ខ១ គ១ កងឯកភាពលេខ៧៤ បញ្ជាការដ្ឋានវិស្វកម្ម
២៨-	ពលបាលឯក	**វ៉ាន់ សារឿន**	074177 នាយរងក្រុម១ ខ៣ គ៤ កងស្ពានបាផ្តល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
២៩-	ពលបាលឯក	**ផន សុភាព**	083434 នាយក្រុម២ ខ៣ គ៣ កងស្ពានបាផ្តល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
៣០-	ពលបាលឯក	**ប៉ាត ផល្លា**	221867 នាយក្រុម២ ខ១ គ៣ កងឯកភាពលេខ៧៤ បញ្ជាការដ្ឋានវិស្វកម្ម
៣១-	ពលបាលទោ	**ជ័យ ណន**	094883 នាយក្រុម១ ខ២ គ២កងស្ពានបាសំណង់អគារលេខ៧៣ បញ្ជាការដ្ឋានវិស្វកម្ម
៣២-	ពលបាលទោ	**ប៉ាល់ កក្កដា**	094561 បុគ្គលិកពេទ្យ កងស្ពានបាស្ពានសាឡាងលេខ៧១ បញ្ជាការដ្ឋានវិស្វកម្ម
៣៣-	ពលបាលទោ	**ប៊ុន ចន្ថា**	228720 នាយក្រុម២ ខ២ គ៣ វរសេនាតូចដឹកជញ្ជូនលេខ៧៩៦ បញ្ជាការដ្ឋានវិស្វកម្ម
៣៤-	ពលបាលទោ	**អ៊ុំ វណ្ណៈ**	222040 នាយក្រុម គ៣ កងស្ពានបាផ្តល់លេខ៧១៨ បញ្ជាការដ្ឋានវិស្វកម្ម
៣៥-	ពលបាលត្រី	**ខឹម ចំរ៉ុង**	221351 បុគ្គលិករដ្ឋបាល វរសេនាតូចដឹកជញ្ជូនលេខ៧៩៦ បញ្ជាការដ្ឋានវិស្វកម្ម
៣៦-	ពលបាលត្រី	**ថែម វិរឌ្ឍន៍**	221600 បុគ្គលិក រដ្ឋបាល កងស្ពានបាស្ពានសាឡាងលេខ៧១ បញ្ជាការដ្ឋានវិស្វកម្ម
៣៧-	ពលបាលត្រី	**ឈួន ឈុំ**	221468 មេបញ្ជាការរង ខ៣ គ៤ កងស្ពានបាស្ពានសាឡាងលេខ៧១ បញ្ជាការដ្ឋានវិស្វកម្ម
៣៨-	ពលបាលត្រី	**ប៊ូ សារឿន**	221564 នាយក្រុម២ ខ៣ គ៤ កងស្ពានបាស្ពានសាឡាងលេខ៧១ បញ្ជាការដ្ឋានវិស្វកម្ម
៣៩-	ពលបាលត្រី	**សម្បត្តិ សុខន**	221304 នាយរងក្រុម កងការពារ បញ្ជាការដ្ឋានវិស្វកម្ម
៤០-	ពលបាលត្រី	**នី និត**	238412 នាយរងក្រុម១ ខ១ គ១ កងស្ពានបាផ្តល់លេខ៧១៦បញ្ជាការដ្ឋានវិស្វកម្ម
៤១-	ពលបាលត្រី	**ភន វ៉ាន់នី**	238445 នាយរងក្រុម១ ខ៣ គ១ កងស្ពានបាផ្តល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
៤២-	ពលបាលត្រី	**សយ វុទ្ធី**	108791 នាយរងក្រុម២ ខ២ គ៣ កងស្ពានបាផ្តល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
៤៣-	ពលបាលត្រី	**សោន ផល្លា**	228848 នាយរងក្រុម៣ ខ៣ គ៣ កងស្ពានបាផ្តល់លេខ៧១៦ បញ្ជាការដ្ឋានវិស្វកម្ម
៤៤-	ពលបាលត្រី	**ហង់ ផុល**	090557 នាយរងក្រុម៣ ខ៣ គ៤ កងស្ពានបាផ្តល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
៤៥-	ពលបាលត្រី	**សេង មករា**	131775 នាយរងក្រុម១ ខ១ គ៤ កងស្ពានបាផ្តល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម
៤៦-	ពលបាលត្រី	**ឆាយ សុភ័ក្រ**	131809 បុគ្គលិកជួសជុល កងស្ពានបាផ្តល់លេខ៧១៣ បញ្ជាការដ្ឋានវិស្វកម្ម

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការ បញ្ជាការដ្ឋានវិស្វកម្ម កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងជំនួយការក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ឈាវ ឡា** ជាជំនួយការក្រសួងមហាផ្ទៃ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : លោក **ឈាវ ឡា** ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែរបស់ខ្លួន ដោយគិតចាប់តាំងពីថ្ងៃចូលនិវត្តន៍ ។ ចំនួនប្រាក់ឧបត្ថម្ភប្រចាំខែត្រូវបានកំណត់ដូចក្នុងលិខិតលេខ ២៥៣ សជណ ចុះថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវឧបត្ថម្ភសម្រាប់មុខតំណែងជំនួយការក្រសួងមហាផ្ទៃ ឋានៈស្មើប្រធាននាយកដ្ឋាន។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៦៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ** ប្រគេន និងផ្តល់ជូនសប្បុរសជន ចំនួន១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាធម្មសភា កុដិ សាលារៀន ផ្លូវលំ ប្រឡាយទឹក ស្រះទឹក និងសមិទ្ធផលជាច្រើនទៀត ស្ថិតនៅក្នុងឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

១-ព្រះតេជគុណសុវណ្ណជោត **សេន ឈុន** គង់នៅវត្តព្រះពុទ្ធអណ្តែត បច្ច័យចំនួន ២១.០០០ ដុល្លារ

២-ព្រះតេគុណធម្មរក្ខិតោ **ដួង ចន្ធូ** គង់នៅវត្តពាមមង្គលបូរី បច្ច័យចំនួន ២០.៧០០ ដុល្លារ

៣-ព្រះតេជគុណសុកប្បញ្ញោ **ធី ម៉ានី** គង់នៅវត្តឧណ្ណាលោម បច្ច័យចំនួន ២០.២០០ ដុល្លារ

៤-លោក **មាស សុផល** អគ្គនាយករងរដ្ឋបាលការពារធនធានធម្មជាតិ នៃក្រសួងបរិស្ថាន ថវិកាចំនួន ២០.៣០០ ដុល្លារ

៥-លោក **នួន រដ្ឋា** អគារធិការរង នៃក្រសួងបរិស្ថាន ថវិកាចំនួន ២០.១០០ ដុល្លារ

៦-លោក **រស់ សុវណ្ណ** អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងបរិស្ថាន ថវិកាចំនួន ២០.០០០ ដុល្លារ

៧-លោក **ចាប ម៉ារិទ្ធ** អនុប្រធានការិយាល័យ នៃក្រសួងបរិស្ថាន ថវិកាចំនួន ២០.០០០ ដុល្លារ

៨-លោក **ឆយ ម៉ុនលី** ប្រធានមន្ទីរបរិស្ថានខេត្តតាកែវ ថវិកាចំនួន ២០.០០០ ដុល្លារ

៩-លោក **តាំង ផល** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ២០.០០០ ដុល្លារ

១០-លោកស្រី **លី ហ៊ា** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ២០.០០០ ដុល្លារ

១១-លោកស្រី **លី ណារ៉ា** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ២០.០០០ ដុល្លារ

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តតាកែវ និងសាមីខ្លួនដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ៦៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាធម្មសភា កុដិ សាលារៀន ផ្លូវលំ ប្រឡាយទឹក ស្រះទឹក និងសមិទ្ធផលជាច្រើនទៀត ស្ថិតនៅក្នុងឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ដែលមានរាយនាមដូចខាងក្រោម :

ក~ មេដាយមាសស្ថាបនាជាតិចំនួន ២៩ គ្រឿង ប្រគេន និងផ្តល់ជូន :

១-ព្រះតេជគុណតុលធម្មោ **ពៅ ថុល** ព្រះចៅអធិការវត្តស្តីទីវត្តអង្គប្រិយ៍ បច្ច័យចំនួន ១០.១០០ ដុល្លារ

២-ព្រះតេជគុណថិរធម្មោ **ជុំ សារិន** ព្រះសង្ឃខ្មែរគង់នៅប្រទេសថៃ បច្ច័យចំនួន ១០.១០០ ដុល្លារ

៣-ព្រះតេជគុណមេត្តាបាលោ **ឌុច ចាន់នី** គង់នៅវត្តបទុមវតី បច្ច័យចំនួន ១០.១០០ ដុល្លារ

៤-លោក **សុខ ស៊ីថា** មេឃុំលំចង់ ថវិកាចំនួន ១០.៧០០ ដុល្លារ

៥-លោក **សេក ឆា** អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងបរិស្ថាន ថវិកាចំនួន ១០.៦០០ ដុល្លារ

៦-លោក **គីន យ៉ាងលី** មន្ត្រីក្រសួងបរិស្ថាន ថវិកាចំនួន ១០.៥០០ ដុល្លារ

៧-លោក **ឃឹម ម៉ុន្ធា** ប្រធានការិយាល័យគណនេយ្យរតនាគារខេត្តតាកែវ ថវិកាចំនួន ១០.៤០០ ដុល្លារ

៨-លោក **ញៀម សុវណ្ណារ៉ា** មន្ត្រីពន្ធដារស្រុកសំរោង ថវិកាចំនួន ១០.៣០០ ដុល្លារ

៩-លោក ម៉ែន ពុទ្ធ នាយកវិទ្យាល័យ **ហ៊ុន សែន អង្គប្រីយ៍** ថវិកាចំនួន ១០.២០០ ដុល្លារ

១០-លោក សៅ សុខជា ប្រធានការិយាល័យធម្មការ និងសាសនាស្រុកសំរោង ថវិកាចំនួន ១០.១០០ ដុល្លារ

១១-លោក ឡោភ សារឿន ប្រធានការិយាល័យពី មន្ទីរបរិស្ថានខេត្តតាកែវ ថវិកាចំនួន ១០.១០០ ដុល្លារ

១២-លោក ហ៊ុន ហ៊ិន សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.១០០ ដុល្លារ

១៣-លោក ឪ ភន សាស្ត្រាចារ្យសាកលវិទ្យាល័យបៀលប្រាយ ថវិកាចំនួន ១០.១០០ ដុល្លារ

១៤-លោកស្រី យ៉ែម អែននី សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១០.១០០ ដុល្លារ

១៥-លោកស្រី ផល ម៉ិច ប្រធានការិយាល័យក្រសួងបរិស្ថាន ថវិកាចំនួន ១០.១០០ ដុល្លារ

១៦-លោកស្រី ញឹម សុផល ប្រធានការិយាល័យក្រសួងបរិស្ថាន ថវិកាចំនួន ១០.១០០ ដុល្លារ

១៧-លោក ហ៊ុយ ទ៉ាថវី អនុប្រធានការិយាល័យក្រសួងបរិស្ថាន ថវិកាចំនួន ១០.១០០ ដុល្លារ

១៨-លោកស្រី នាក់ សាមី ជំទប់ទី១ ឃុំលំចង់ ថវិកាចំនួន ១០.១០០ ដុល្លារ

១៩-លោក អ៊ុក ឌឹម សមាជិកក្រុមប្រឹក្សាឃុំលំចង់ ថវិកាចំនួន ១០.០០០ ដុល្លារ

២០-លោក កែវ គ្រឿន សមាជិកក្រុមប្រឹក្សាឃុំលំចង់ ថវិកាចំនួន ១០.០០០ ដុល្លារ

២១-លោក ស្វាយ ឧត្តោ ស្មៀនឃុំលំចង់ ថវិកាចំនួន ១០.០០០ ដុល្លារ

២២-លោក អេង សុខលី ប្រធានការិយាល័យស្ថិតិអត្តសញ្ញាណប័ណ្ណខេត្តតាកែវ ថវិកាចំនួន ១០.០០០ ដុល្លារ

២៣-លោក អ៊ូច ប៊ុណ្ណារះ នាយប៉ុស្តិ៍រដ្ឋបាលឃុំលំចង់ ថវិកាចំនួន ១០.០០០ ដុល្លារ

២៤-លោក សុភ ថន នាយករងវិទ្យាល័យ **ហ៊ុន សែន អង្គប្រីយ៍** ថវិកាចំនួន ១០.០០០ ដុល្លារ

២៥-លោក ឈាង គី នាយកសាលាបឋមសិក្សាអង្គប្រីយ៍ ថវិកាចំនួន ១០.០០០ ដុល្លារ

២៦-លោកស្រី ច៊ាន សរីង សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

២៧-លោក ចាន់ ម៉ឺន សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា ថវិកាចំនួន ១០.០០០ ដុល្លារ

២៨-លោកស្រី មុំ សុផាត សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា ថវិកាចំនួន ១០.០០០ ដុល្លារ

២៩-លោក អ៊ូច សុខុន សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១០.០០០ ដុល្លារ

ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ១១ គ្រឿង ប្រគេន និងផ្តល់ជូន :

១-ព្រះតេជគុណនាថមុនី នុត សៅ ព្រះគ្រូសូត្រស្តាំគង់នៅវត្តអង្គប្រីយ៍ ថវិកាចំនួន ៥.៨០០ ដុល្លារ

២-ព្រះតេជគុណរក្ខិតសីលោ ឡុង សារុន ព្រះគ្រូសូត្រឆ្វេងគង់នៅវត្តអង្គប្រីយ៍ ថវិកាចំនួន ៥.៧០០ ដុល្លារ

៣-លោក វង្ស វណ្ណារ៉ា នាយរងប៉ុស្តិ៍រដ្ឋបាលឃុំលំចង់ ថវិកាចំនួន ៥.២០០ ដុល្លារ

៤-លោក ប៊ុន ហុង នាយករងវិទ្យាល័យ **ហ៊ុន សែន អង្គប្រីយ៍** ថវិកាចំនួន ៥.២០០ ដុល្លារ

៥-លោក កែវ សិរិទ្ធិ នាយកសាលាបឋមសិក្សា **ម៉ុក ម៉ារ៉េត ទួលទ្រា** ថវិកាចំនួន ៥.១០០ ដុល្លារ

៦-លោក ឡោ ស៊ីវុត្ថា នាយកសាលាបឋមសិក្សា **ម៉ុក ម៉ារ៉េត ខ្វារ** ថវិកាចំនួន ៥.០០០ ដុល្លារ

៧-លោក អ៊ុក ស៊ុនលី នាយករងសាលាបឋមសិក្សាអង្គប្រីយ៍ ថវិកាចំនួន ៥.០០០ ដុល្លារ

៨-ឧបាសក **អ៊ុយ ទុំ** ប្រធានអាចារ្យវត្តអង្គប្រីយ៍ ថវិកាចំនួន ៥.០០០ ដុល្លារ

៩-ឧបាសក **ម៉ី ម៉ន** សមាជិកអាចារ្យវត្តអង្គប្រីយ៍ ថវិកាចំនួន ៥.០០០ ដុល្លារ

១០-ឧបាសក **កែវ ហៀង** ប្រធានគណៈកម្មការសាងសង់វត្តអង្គប្រីយ៍ ថវិកាចំនួន ៥.០០០ ដុល្លារ

១១-លោក **ណុប ច្រៀង** ប្រធានមណ្ឌលសុខភាពឃុំលំចង់ ថវិកាចំនួន ៥.០០០ ដុល្លារ

គ~ មេដាយសិរីវឌ្ឍនៈជាតិចំនួន ១៣ គ្រឿង ផ្តល់ជូន :

១-លោក **ឡុង វណ្ណៈ** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.៥០០ ដុល្លារ

២-លោក **ជា សុខុម** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.៥០០ ដុល្លារ

៣-លោក **ឡុង ពេជ្រមុន្នី** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.៤០០ ដុល្លារ

៤-លោក **មាស សុផាត** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.៤០០ ដុល្លារ

៥-លោក **ឡេង យាង** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.០០០ ដុល្លារ

៦-លោក **ម៉ុស សៀងហៃ** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.០០០ ដុល្លារ

៧-លោក **សំ ទីរៈ** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.០០០ ដុល្លារ

៨-លោក **អ៊ុំ ណុប** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.០០០ ដុល្លារ

៩-លោក **ស្វាយ ផាន់** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.០០០ ដុល្លារ

១០-លោក **ឈឿង មឿន** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.០០០ ដុល្លារ

១១-លោក **គង់ ផន** សប្បុរសជននៅខេត្តតាកែវ ថវិកាចំនួន ១.០០០ ដុល្លារ

១២-លោក **គាត បុល** នាយករងសាលាបឋមសិក្សា **ម៉ុក ម៉ារ៉ែត ទួលទ្រា** ថវិកាចំនួន ១.០០០ ដុល្លារ

១៣-លោក **ចាន់ សារ៉ែត** នាយករងសាលាបឋមសិក្សា **ម៉ុក ម៉ារ៉ែត ខ្វាវ** ថវិកាចំនួន ១.០០០ ដុល្លារ

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១.-

បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ចំនួន០១គ្រឿង ជូនលោកសាស្ត្រាចារ្យ **ក្លូត ឌុយមួរហ្ស៊ីយេ** (Prof. Claude DUMURGIER) ជនជាតិបារាំង ដែលមានស្នាដៃល្អដោយបានមកបំពេញបេសកកម្ម នៅកម្ពុជា តាំងពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២០០២ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងគុណធម៌ លើវិស័យសុខាភិបាល នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចូលរួមក្នុងការបង្កើតថ្នាក់ឯកទេសក្រោយបរិញ្ញាបត្រ ផ្នែកវះកាត់ និងរកកន្លែងអោយនិស្សិតធ្វើកម្មសិក្សាផ្នែកវះកាត់ នៅប្រទេសបារាំង ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **អោក មុនី** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ១ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ៧៤៨ ឧ.ស.ថ.ក.ន-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៤៥/១២ ត.ត.ស.ព ចុះថ្ងៃទី២៥.០៥.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ចាផាណា (ខេមបូឌា) ចុះថ្ងៃទី២៦.០៦.២០១៣

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ចាផាណា (ខេមបូឌា) (JAPANA (CAMBODIA) CO., LTD.) តំណាងដោយ លោក MIZUNO TAIZO សញ្ជាតិជប៉ុន អាយុ៦៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TH8165059 ចុះថ្ងៃទី ១៩.០៦.២០១៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ 1 Ling Jiang Road, Development Zone for High & New Tech Wuxi of China. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
សម្លៀកបំពាក់កីឡា, ស្រោមដៃកីឡា	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

ផ្លាកឈ្មោះរោងចក្រ ៖ " *រោងចក្រកាត់សម្លៀកបំពាក់កីឡា និងស្រោមដៃកីឡា ចាផាណា (ខេមបូឌា)* "

ទីតាំងរោងចក្រ ៖ " *តំបន់សេដ្ឋកិច្ចពិសេសតាយសេងបាវិត សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង* "

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៦៤៩ ឧរថ.កឧ/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៣៨២/១៣ គ.វ.ក ចុះថ្ងៃទី២១.០៦.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ីកូ (ភ្នំពេញ) ខូអិលធីឌី ចុះថ្ងៃទី១១.០៦.២០១៣

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីកូ (ភ្នំពេញ) ខូអិលធីឌី (SHEICO (PHNOM PENH) CO., LTD.) តំណាងដោយ លោកស្រី ជីមហេងស៊ីង សញ្ជាតិខ្មែរ អាយុ២៧ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០៧៥០៦៩៧ ចុះថ្ងៃទី០៧.០៩.២០១១ មានអាសយដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ២៣២ EoE1 ផ្លូវលេខ៩៣ ភូមិ៦ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ីកូ (ភ្នំពេញ) ខូអិលធីឌី "*
- **ទីតាំងរោងចក្រ ៖** *" ផ្លូវជាតិលេខ៣ ភូមិស្រែញ៉រ សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៦៥០ ឧរក.ភឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៥៨៦/១១ ម.ត.ស.ព ចុះថ្ងៃទី១៥.១១.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វ្រាន់ ភែកឃិជីង (ខេមបូឌា) ចុះថ្ងៃទី១៩.០៦.២០១៣

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វ្រាន់ ភែកឃិជីង (ខេមបូឌា)(FRONT PACKAGING (CAMBODIA) LTD.) តំណាងដោយ លោក CHEN WENTAO សញ្ជាតិចិន អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខG49076052 ចុះថ្ងៃទី ១៨.០៣.២០១១ មានអាសយដ្ឋានបច្ចុប្បន្នៈ #305, St.10, Shandong, Qingdao Province, China. ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោមៈ

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្ភារៈវេចខ្ចប់ពីប្លាស្ទិក	២២២០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ផ្លាកឈ្មោះរោងចក្រ ៖ " *រោងចក្រផលិតសម្ភារៈវេចខ្ចប់ ប្រ៊ាន់ តៃកឃឺជីង (ខេមបូឌា)* "

ទីតាំងរោងចក្រ ៖ " *តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង* "

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

ចម្លងជូន:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ